# មហាមង្គលឆ្លងព្រះពុទ្ធត្រាស់ដឹង

## គ្រប់២៦០០ឆ្នាំ



## វិសាខបូជា ព.ស. ២៥៥៥/២០១១

ធម្មបណ្ឌិត ហេង មណីចិន្តា

# **អនុមោទនាខួបព្រះពុទ្ធត្រាស់ដឹង គ្រប់២៦០០ឆ្នាំ/វិសាខបូជា ២០១១**

*រៀបរៀងនិងរចនាដោយ ហេង មណីចិន្តា*

*©រក្សាសិទ្ធិគ្រប់យ៉ាង ដោយ ហេង មណីចិន្តា*

*បោះពុម្ពជាធម្មទានលើកទី១ ចំនួន ២៦០០ក្បាល*

*ក្នុងឱកាសបុណ្យវិសាខបូជា ថ្ងៃទី ១៧ ឧសភា ២០១១*

*ដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍*

*វត្តអន្ទង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង*

*បើចង់បោះពុម្ពសៀវភៅនេះជាធម្មទាន សូមទាក់ទង*

*លោក សុខ សុផល*

*អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍*

012—553 123

*គ្របក្រៅ*

*«ពុទ្ធនិមិត្ត» សិល្បៈគំនូរយ័ន្ត្របុរាណខ្មែរ*

*រចនាពណ៌បន្ថែមដោយលោក សុខ សុផល*

# អារម្ភកថា

ថ្ងៃ១៥កើត ខែវិសាខ គឺជាទិវាប្រវត្តិសាស្ត្រដ៏សំខាន់មួយដែលពុទ្ធសាសនិកជនគ្រប់រូបទូទាំងពិភពលោក តែងប្រារព្ធរំលឹកជារៀងរាល់ឆ្នាំ តាមរយៈពិធីបុណ្យប្រពៃណីពុទ្ធសាសនា វិសាខបូជា។ វិសាខបូជាដែលប្រារព្ធឡើងក្នុងឆ្នាំ២០១១នេះ ដើម្បីរំលឹកដល់ថ្ងៃកំណើត(ខួបទី២៦៣៥) ថ្ងៃចូលបរិនិព្វាន(ខួបទី២៥៥៥) និងថ្ងៃត្រាស់ដឹង(ខួបទី២៦០០) របស់ព្រះសមណគោត្តម ដែលជាព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូនៃយើង។ អភិលក្ខិតសម័យទាំងបីនេះ កើតឡើងនៅចំថ្ងៃ១៥កើតខែវិសាខតែមួយ ខុសគ្នាតែឆ្នាំប៉ុណ្ណោះ។ ថ្ងៃនេះដែរ ក៏ជាថ្ងៃដែលអង្គការសហប្រជាជាតិបានកំណត់យកជាទិវាអន្តរជាតិ ចាប់តាំងពីថ្ងៃទី ១៥ធ្នូ ១៩៩៩ មកម្ល៉េះ ដែលជាការទទួលស្គាល់ជាសកលអំពីការចូលរួមចំណែករបស់ព្រះពុទ្ធសាសនាក្នុងពិភពលោកជាងពីរពាន់ប្រាំរយឆ្នាំមកនេះ ហើយនិងកំពុងបន្តនូវឥទ្ធិពលរបស់ខ្លួនក្នុងការលើកស្ទួយចិត្តវិញ្ញាណរបស់មនុស្សជាតិជារៀងរហូត។

ដោយឡែកនៅក្នុងឆ្នាំព.ស.២៥៥៥ ឆ្នាំសាកល២០១១នេះ កម្ពុជាយើងបានជួបនូវព្រឹត្តិការណ៍មួយទៀតដែលរឹតតែសំខាន់ នុះគឺឆ្នាំនេះជាខួបគម្រប់២៦០០ឆ្នាំនៃការបានត្រាស់ដឹងជាព្រះពុទ្ធ ឬ**ខួបគម្រប់២៦០០ឆ្នាំនៃ សម្ពុទ្ធត្វជយន្តិ** របស់ព្រះសមណគោត្តម ព្រោះថាពុទ្ធសករាជយើងនេះ ចាប់រាប់ជាឆ្នាំទី១ មួយថ្ងៃក្រោយព្រះអង្គចូលបរិនិព្វាន បើគិតមកដល់ថ្ងៃនេះ បាន២៥៥៥ហើយ។ ឯព្រះបរមគ្រូរបស់យើង ព្រះអង្គត្រាស់ដឹងមុនពុទ្ធសករាជ ៤៥ឆ្នាំ ដូច្នេះ ឆ្នាំនេះ ចាប់តាំងពីព្រះអង្គត្រាស់ដឹងមក មានចំនួនគ្រប់២៦០០ឆ្នាំគត់ ត្រឹមថ្ងៃ១៥កើតខែពិសាខ ឆ្នាំថោះត្រីស័ក ព.ស. ២៥៥៥ នេះ ដែលត្រូវនឹងថ្ងៃអង្គារ ទី១៧ ខែឧសភា ឆ្នាំ២០១១។

ខ្ញុំសប្បាយចិត្តណាស់ ដែលបានកើតទាន់ខួប២៦០០ឆ្នាំនៃការត្រាស់ដឹងនេះ បានបុណ្យកុសលច្រើនណាស់ព្រោះបានចូលរួមចំណែកក្នុងការផ្តល់ជាគំនិតជូនឯកឧត្តម មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការនិងកិច្ចការសាសនា ក្នុងការយកបុណ្យ

វិសាខបូជាឆ្នាំនេះជាខួប២៦០០ឆ្នាំនៃការត្រាស់ដឹងរបស់ព្រះពុទ្ធបរមគ្រូ ដោយបានដាក់ស្នើទៅសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំយកវិសាខបូជាឆ្នាំនេះ ធ្វើជាពិធីបុណ្យជាតិក្រោមការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល និងមានចិត្តបីតិសោមនស្សដែលបានរៀបរៀងសៀវភៅនេះសម្រាប់ពុទ្ធបរិស័ទបានអាននិងស្វែងយល់ ព្រមទាំងបានទុកជាកេរ្តិ៍ដំណែលក្នុងព្រះពុទ្ធសាសនាតទៅផង។

កូនសៀវភៅនេះ មួយផ្នែកបានសរសេរឡើងកាលពីឆ្នាំ២៥៥៤ និងបានបន្ថែមខ្លះទៀត ដោយដកស្រង់ពីសៀវភៅឈ្មោះ **ពុទ្ធនាទៈ** ដែលខ្ញុំសរសេរឡើងជាពិសេសសម្រាប់ឆ្នាំ២៥៥៥នេះ តែមិនមានឱកាសបោះពុម្ពទាន់ ព្រោះគ្រាស់ និងរកថវិកាបោះពុម្ពមិនទាន់។ សៀវភៅនេះធ្វើឡើងដើម្បីបោះពុម្ពឲ្យទាន់សម្រាប់ថ្ងៃវិសាខបូជា ២៥៥៥នេះតែប៉ុណ្ណោះ។

ខ្ញុំសូមឧទ្ទិសផលានិសង្សដែលកើតបានពីសៀវភៅនេះ ប្រគេន ថ្វាយ និងជូនចំពោះវិញ្ញាណក្ខន្ធអតីតព្រះសង្ឃ ព្រះមហាក្សត្រ អ្នកដឹកនាំប្រទេស ពុទ្ធបរិស័ទ និងប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលបានខិតខំតស៊ូប្តូរនឹងជីវិតខ្លួន ដើម្បីឧបត្ថម្ភ គាំទ្រ រក្សា ការពារ និងស្តារឡើងវិញនូវព្រះពុទ្ធសាសនា ទុកឲ្យពួកយើងបានគោរពបូជារហូតដល់ថ្ងៃនេះ។ សូមវិញ្ញាណក្ខន្ធទាំងអស់នោះ អនុមោទនានូវអានិសង្សនេះ និងសូមបានទៅកាន់សុគតិភពដែលកាន់តែប្រសើរឡើង និងសូមវិញ្ញាណក្ខន្ធទាំងនោះមេត្តាជួយប្រសិទ្ធិពរបវរសួស្តីជ័យមង្គលវិបុលសុខដល់ប្រជាពលរដ្ឋកម្ពុជា សូមឲ្យបានជួបតែនឹងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ និងសូមចម្រើនក្នុងអរិយមគ្គទាំងឡាយដោយឆាប់រហ័ស កុំបីឃ្លៀងឃ្លាតឡើយ។

ពីទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ ហេង មណីចិន្តា
អន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង

# ថ្ងៃត្រាស់ដឹង

*ជាថ្ងៃដែលមានសារៈសំខាន់បំផុត ព្រោះថ្ងៃនេះ*

*មនុស្ស*
*សាមញ្ញ*
*ម្នាក់ដែល*
*ធ្លាប់ពោរ*
*ពេញដោយ*
*កិលេស គឺ*
*រាគៈទោសៈ*
*និងមោហៈ*



*បានត្រាស់*
*ដឹងពីវិធី*
*រំលត់នូវ*
*កិលេស*
*និងបង្កើត*
*សន្តិភាព*
*ក្នុងជីវិត*
*ព្រះអង្គ*

*បានជាលើកដំបូងបង្អស់ក្នុងពិភពលោក។ ការរកឃើញនេះ*

**បានធ្វើឲ្យលោកក្លាយពីមនុស្សធម្មតាម្នាក់ទៅជាព្រះពុទ្ធ**

*ដែលជាអ្នកបង្កើតពុទ្ធសាសនានាបច្ចុប្បន្ន!!!*

*ព្រះពុទ្ធភៃសជ្យគុរុ ឬ ព្រះពុទ្ធជាគ្រូពេទ្យ*
*ប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ*
*រូបថតដោយ ហេង មណីចិន្តា ឆ្នាំ២០០៩*

# អ្នកណាជាព្រះពុទ្ធ

*ពាក្យថា***ពុទ្ធ** *ជាភាសាបាលីនិងភាសាសំស្ក្រឹត អានថា ពុធធៈ ។ ពាក្យនេះមានសេចក្តីលំបាក ក្នុងការពន្យល់ឲ្យយល់បានជាភាសានិយាយណាស់ ដូច្នេះហើយ ទើបបូរាណាចារ្យខ្មែរយើង មិនប្រែពាក្យនេះជាភាសាខ្មែរទេ គឺប្រើពាក្យ* **ពុទ្ធ***(អានថាពុធ) ដដែល ព្រោះលោកខ្លាចប្រែមិនអស់សេចក្តី ក៏នឹងកើតជាបាបបាន។ ការយល់អំពីពុទ្ធភាវៈតម្រូវឲ្យយើងស្រាវជ្រាវអំពីគម្ពីរព្រះត្រៃបិដក អដ្ឋកថា ដីកា អនុដីកា និងគម្ពីរផ្សេងៗទៀតឲ្យបានច្រើន រួមទាំងមតិផ្សេងៗរបស់អ្នកប្រាជ្ញពុទ្ធសាសនាក្នុងសាកលលោកផងដែរ។ ជាពិសេស គឺការបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ រហូតទាល់តែអាចបានទទួលនូវរសជាតិរបស់ពុទ្ធភាវៈដោយខ្លួនឯង ទើបអាចដឹងនិងនិយាយដោយខ្លួនឯងបានថា ឱ! អញ្ចឹងទេតើដែលហៅថាពុទ្ធភាវៈហ្ន!*

*សម្រាប់យុវវ័យ ការសួរថាអ្នកណាជាព្រះពុទ្ធ មិនមែនជាចម្លើយដែលងាយស្រួលក្នុងការឆ្លើយទេ។ តាមពិតទៅ ពុទ្ធសាសនិកយើងជាច្រើនក៏មិនអាចនឹងឆ្លើយបានដោយងាយៗនោះដែរ។ ការស្គាល់ព្រះពុទ្ធរបស់ពួកយើងជាខ្មែរ ជាដំបូងគឺការដែលមាតាបិតានាំយើងទៅវត្ត ហើយឲ្យយើងលើកដៃសំពះរូបព្រះពុទ្ធបដិមាដែលនៅក្នុងវិហារឬសាលាឆាន់ ដោយប្រាប់ថា «លើកដៃដូងកាក់កូន លើកដៃសំពះ***ព្រះអង្គ** *ណាកូនណា បានបុណ្យ បានសេចក្តីសុខ!»។*

*ដូច្នេះ ការស្គាល់របស់យើង គឺស្គាល់រូបសំណាក រូបចម្លាក់ រូបគំនូរ ដែលតំណាងឲ្យព្រះពុទ្ធ ហើយដែលភាគច្រើននោះ យើងហៅថា«ព្រះអង្គៗ» នោះឯង។ ការយល់ដឹងអំពីព្រះអង្គរបស់យើងជាបន្តបន្ទាប់មកទៀតនោះ ក៏មានភាពមិនច្បាស់លាស់ ព្រោះពុំមានការសិក្សាឲ្យបានជ្រៅជ្រះ លើកលែងតែអ្នកដែលបានស្តាប់ព្រះធម៌ទេសនាដែលព្រះសង្ឃសម្តែង ឬបានបួសរៀនក្នុងព្រះពុទ្ធសាសនា។*

*ពុទ្ធបដិមា ឬ រូបគំនូរដែលយើងហៅថា* ***ព្រះពុទ្ធៗ*** *នេះ មិនមែនមានឈ្មោះថាព្រះពុទ្ធ ពីកំណើតទេ ហើយក៏មិនមែនជាព្រះពុទ្ធពីកំណើតដែរ ដូចដែលមានសម្ដែងនៅក្នុងសោឡសមាណវកប្បញ្ហានិគមនិទ្ទេស នៃគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស ព្រះត្រៃបិដកខ្មែរលេខ៦៨ ទំព័រ ១០៦-១០៨ថាៈ «****ព្រះនាមព្រះពុទ្ធនុះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្តនិងអាមាត្យថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកញាតិនិងសារលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនទេវតាថ្វាយទេ ព្រះនាមថាព្រះពុទ្ធនុះ (ជា)របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគជាព្រះនាមកើតនៅក្នុងទីបំផុតនៃវិមោក្ខ។ បញ្ញត្តិថាព្រះពុទ្ធនេះ កើតព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនុះ (លោកពោលថា) ព្រះពុទ្ធៗ*** *១...ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ(**ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ**) **២**...ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ញុំាងពពួកសត្វឲ្យត្រាស់ដឹង(**ពោធេតា បជាយាតិ ពុទ្ធោ**) **៣**...ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គដឹងធម៌ទាំងពួង(**សព្វញ្ញុតាយ ពុទ្ធោ**) **៤**...ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គឃើញធម៌ទាំងពួង(**សព្វទស្សាវិតាយ ពុទ្ធោ**) **៥**...ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់(**អភិញ្ញេយ្យតាយ ពុទ្ធោ**) **៦**...ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ(**វិកសិតាយ ពុទ្ធោ**) **៧**...ឈ្មោះថាព្រះពុទ្ធ ព្រោះគេពោលថាព្រះអង្គមានអាសវៈអស់ហើយ(**ខីណាសវ សង្ខាតេន ពុទ្ធោ**) **៨**...ឈ្មោះថាព្រះពុទ្ធ ព្រោះគេពោលថាព្រះអង្គមានឧបក្កិលេសចេញហើយ(**និរុបក្កិលេសសង្ខា តេន ពុទ្ធោ**) **៩**...ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ(**ឯកន្តវីតរាគោតិ ពុទ្ធោ**) **១០**...ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ(**ឯកន្តវីតទោសោតិ ពុទ្ធោ**) **១១**...ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈដោយចំណែកមួយ(**ឯកន្តវីត មោហោតិ ពុទ្ធោ**) **១២**...ឈ្មោះ*

ជាព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយដោយចំណែកមួយ(**ឯកន្ត និក្កិលេសោតិ ពុទ្ធោ**) **១៣**...ឈ្មោះជាព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង(**ឯកាយនមគ្គំ គតោតិ ពុទ្ធោ**) **១៤**...ឈ្មោះជាព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតិដទៃក្រៃលែងជាង(**ឯកោ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោតិ ពុទ្ធោ**) **១៥**...ឈ្មោះជាព្រះពុទ្ធ ព្រោះហេតុទ្រង់កំចាត់បង់សេចក្ដីល្ងង់ ព្រោះការបាននូវប្រាជ្ញា(**អពុទ្ធិវិហត ត្តា ពុទ្ធិប្បដិលាភា ពុទ្ធោ**)។

ត្រង់ពាក្យថា «ព្រះនាមថាព្រះពុទ្ធនុះ ជាព្រះនាមកើតនៅក្នុងទីបំផុតនៃវិមោក្ខ» អាចបញ្ជាក់ប្រាប់យើងថា ព្រះពុទ្ធនេះមិនមែនកើតពីផ្ទៃមាតាដូចដែលយើងគិតនោះទេ **អ្នកដែលកើតពីផ្ទៃមាតាគឺជាមនុស្ស**។ សម្រាប់មនុស្សណាដែលបានខំប្រឹងប្រែងអភិវឌ្ឍន៍កាយ វាចា និងចិត្តរបស់ខ្លួន រហូតទាល់តែដល់ទីបំផុតនៃវិមោក្ខ គឺបានចេញរួចផុតស្រឡះពីកិលេសទាំងពួង មានសេរីភាពផុតពីការត្រួតត្រារបស់កិលេសទាំងពួង មានជាអាទិ៍គឺ រាគៈ ទោសៈ និងមោហៈ មនុស្សនោះក៏នឹងបានឈ្មោះថាជា **ពុទ្ធ**។ សម្រាប់ព្រះពុទ្ធដែលយើងគោរពបូជាថ្វាយបង្គំនាបច្ចុប្បន្ននេះ មុននឹងដល់ទីបំផុតនៃវិមោក្ខ គឺជាមនុស្សម្នាក់ដែលកើតនៅក្នុងប្រទេសនេប៉ាល់ពីអតីតកាល គឺពី២៦៣៥ឆ្នាំមុន នៅក្នុងត្រកូលក្សត្រ ដែលមាន**មាតានាមសិរិមហាមាយា** និង**បិតានាមសុទ្ធោទនៈ** សោយរាជ្យក្នុងនគរកបិលពស្តុ។ កាលប្រសូត្រមកមាតាបិតាថ្វាយព្រះនាមថា**សិទ្ធត្ថៈ** ហើយបន្ទាប់មកព្រះមាតាក៏ចូលទិវង្គតបាត់ទៅពេលដែលព្រះសិទ្ធត្ថៈទើបតែបានព្រះជន្ម៧ថ្ងៃ។ ព្រះអង្គត្រូវទទួលការចិញ្ចឹមបីបាច់ពីព្រះបិតានិងព្រះមាតុច្ឆា(ម្ដាយមីង) ព្រះនាម**បជាបតិគោតមី** ជាបន្ត។

ព្រះសិទ្ធត្ថបានទទួលការចិញ្ចឹមបីបាច់រក្សាក្នុលក្ខណៈជាព្រះរាជបុត្រ បានទទួលការសិក្សារៀនសូត្រខ្ពង់ខ្ពស់ទៅតាមវិស័យការសិក្សានាជំនាន់នោះ។ លុះព្រះជន្មបាន១៦វស្សា ព្រះសិទ្ធត្ថក៏បានរៀបអភិសេកជាមួយម្ចាស់ក្សត្រីព្រះនាម**ពិម្ពា**

**យសោធរា** ដែលមកពីនគរជិតខាងគ្នា។ ទាំងពីរព្រះអង្គ មានព្រះរាជបុត្រមួយអង្គ នៅក្នុងព្រះជន្ម២៩វស្សា ដោយថ្វាយព្រះនាមថា **រាហុលកុមារ**។

នៅក្នុងព្រះជន្ម២៩វស្សានេះឯង ដែលព្រះសិទ្ធត្ថបានចាកចេញពីក្រុមគ្រួសារនិងរាជ្យសម្បត្តិ ធ្វើដំណើរទៅបួសជាសមណៈដើម្បីស្វែងរកសភាវៈដែលមិនមានសេចក្តីទុក្ខ។ ដោយការបដិបត្តិធម៌ដ៏មានសេចក្តីព្យាយាមខ្លាំងក្លាជាទីបំផុតអស់រយៈពេល៦ឆ្នាំ ព្រះអង្គក៏បានរកឃើញ(ត្រាស់ដឹង)នូវវិធីដើម្បីរំលត់នូវសេចក្តីទុក្ខដែលមាននៅក្នុងជីវិតរបស់ព្រះអង្គ។ ជាទីបំផុត ព្រះអង្គក៏អាចកំចាត់បាននូវសេចក្តីទុក្ខទាំងនោះបាន **ដោយខណៈនៃការដែលសភាវៈជាទុក្ខទាំងឡាយនោះរលត់បាត់ទៅនោះឯង (ទីបំផុតនៃវិមោក្ខ) ដែលបញ្ញត្តិ(ពាក្យ)ថា ពុទ្ធ បានកើតឡើង(វិមោក្ខន្តិកមេតំ ពុទ្ធានំ)** នៅក្នុងលោកនេះ ដោយនៅក្នុងគម្ពីរព្រះត្រៃបិដកបានបរិយាយថា ខណៈនោះឯង ទេវតាទាំងឡាយដែលតែងតែរង់ចាំឃ្លាំមើលដំណើរនៃការស្វែងរកការរំលត់ទុក្ខរបស់ព្រះសិទ្ធត្ថ បានបន្លឺវាចាកងរំពងថា «**ពុទ្ធោ លោកេ ឧប្បន្នោ**» ប្រែថា«**ព្រះពុទ្ធកើតឡើងក្នុងលោកហើយៗ**»។ ហេតុការណ៍នេះកើតឡើងនៅរាត្រី១៥កើត ខែពិសាខ ឆ្នាំរកា ពេលជិតភ្លឺ មុនពុទ្ធសករាជ៤៥ឆ្នាំ ឬពី២៦០០ឆ្នាំមុន។

## គុណធម៌ព្រះពុទ្ធ

ក្នុងរយៈពេល៤៥ឆ្នាំក្រោយពីថ្ងៃត្រាស់ដឹងនេះមក ព្រះពុទ្ធអង្គបានបង្រៀនមនុស្សជាតិទាំងឡាយដ៏ច្រើនមិនអាចប្រមាណបាន នូវមគ្គវិធីដែលព្រះអង្គបានរកឃើញនោះ ឲ្យយកទៅកំចាត់នូវកិលេសអាសវៈទាំងពួងចេញពីខន្ធសន្តានបានដូចព្រះអង្គដែរ(**ពោធេតា បជាយាតិ ពុទ្ធោ**)។ ក្នុងរយៈពេល៤៥ឆ្នាំនេះ ព្រះអង្គបានទទួលនូវការគោរពកោតសរសើរពីសំណាក់មហាជន និងបានទទួលនូវការប្រសិទ្ធិនាមផ្សេងៗជាច្រើនទៅតាមគុណធម៌ដែលព្រះអង្គមានចំពោះមនុស្សជាតិ ដែលពួកយើងតែងយកមកសូត្រជាធម៌នមស្សការរំលឹកគុណព្រះពុទ្ធរតនៈ ដោយមាន

ទាំងអស់ចំនួន១០ ព្រះគុណគឺៈ

១. **អរហំ** ព្រះអង្គឆ្ងាយចាកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា

២.**សម្មាសម្ពុទ្ធោ** ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ

៣. **វិជ្ជាចរណសម្បន្នោ** ព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ វិជ្ជា៨ និង ចរណៈ១៥

៤. **សុគតោ** ព្រះអង្គមានដំណើរទៅកាន់អមតៈមហានិព្វាន

៥. **លោកវិទូ** ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក

៦. **អនុត្តរោ** ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលស្មើគ្មាន

៧. **បុរិសទម្មសារថិ** ព្រះអង្គជាអ្នកទូន្មានមនុស្សដែលមានឧបនិស្ស័យ

៨. **សត្ថាទេវមនុស្សានំ** ព្រះអង្គជាសាស្តាចារ្យ នៃមនុស្សនិងទេវតា

៩. **ពុទ្ធោ** ព្រះអង្គត្រាស់ដឹងអរិយសច្ចៈ ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង

១០. **ភគវា** ព្រះអង្គមិនត្រឡប់មកកើតទៀតទេ

# តើព្រះពុទ្ធត្រាស់ដឹងអ្វី

## មជ្ឈិមាបដិបទា

«**ឯតេ តេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបគម្មមជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ។** ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាល មិនលាយឡំដោយអន្តធម៌ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹង ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីនិព្វាន។»

***សេចក្ដីប្រតិបត្តិជាកណ្ដាល*** *ជាភាសាបាលីហៅថា**មជ្ឈិមាបដិបទា**។ ពាក្យ «មជ្ឈិមាបដិបទា» នេះតែងប្រែថា **សេចក្ដីប្រតិបត្តិជាកណ្ដាល** ឬផ្លូវកណ្ដាល តែក្នុងទីនេះ ខ្ញុំសូមប្រែថា **ការប្រតិបត្តិជាមធ្យម** ឬ ផ្លូវមធ្យម ឬមធ្យមប្រតិបត្តិវិញ ព្រោះថា ពាក្យមធ្យម(សំស្ក្រឹត) នេះស្មើនឹងពាក្យមជ្ឈិម(បាលី)។ បើនិយាយថា«ជាកណ្ដាល» យើងតែងតែសួរថាត្រង់ណាទៅដែលហៅថាកណ្ដាល តែបើនិយាយថា«ជាមធ្យម» យើងអាចនឹងងាយយល់បានជាង។ **ការប្រតិបត្តិជាមធ្យម** គឺជាការប្រតិបត្តិដែលជៀសវាងការជ្រុលនិយមទាំងសងខាង(អន្តធម៌) មិនតឹងហួសហេតុពេក(អត្តកិមថានុយោគ) និងមិនធូររលុងពេក(កាមសុខល្លិកានុយោគ) ដែលអាចប្រៀបទៅនឹងការដែលតន្ត្រីករដ៏ចំណានម្នាក់រឹតខ្សែចាប៉ីឬហ្គីតា បើរឹតតឹងពេកសម្លេងដែលលាន់ចេញមកក៏នឹងតឹងស្រួយ ហើយនឹងអាចដាច់បើសិនជានៅតែរឹតថែមទៀត។ តែបើរឹតខ្សែចាប៉ីឬហ្គីតានោះមិនដល់កម្រិតសម្លេងទេ សម្លេងនោះនឹងមិនពីរោះឡើយ។ ខ្មែរយើងតែងហៅសម្លេងដែលរឹតមិនត្រូវនេះថាជា «សម្លេងឈ្វើយ ឬរឹតមិនត្រូវខ្នង់»។*

***ការប្រតិបត្តិជាមធ្យម*** *ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងទុកនេះ ជាការអនុវត្តន៍ដែលទាក់ទងទៅនឹងការមានជីវិត ឬការរស់នៅរបស់មនុស្សយើងជារៀងរាល់ថ្ងៃ ដោយព្រះសម្មាសម្ពុទ្ធអង្គទ្រង់ពិចារណាឃើញថា ការរស់នៅឬការមានជីវិតរបស់មនុស្ស ឬការដែលមនុស្សម្នាក់អាចហៅថា«មានជីវិត»នោះ លុះត្រាតែមនុស្សនោះមានៈ ១-ទស្សនៈឬការយល់ឃើញ(ទិដ្ឋិ) ២-មានការគិត(សង្កប្បៈ) ៣-មានការនិយាយស្ដី(វាចា) ៤-មានអំពើឬកម្ម(កម្មៈ) ៥-មានការចិញ្ចឹមជីវិត(អាជីវៈ) ៦-មានសេចក្ដីព្យាយាម(វាយាមៈ) ៧-មានការរលឹក(សតិ) និង៨-មានចិត្ត(សមាធិ)។ អង្គទាំង៨នេះ មានឥទ្ធិពលទៅលើដំណើរជីវិតរបស់មនុស្សជានិច្ច បើអង្គទាំង៨នេះប្រព្រឹត្តទៅក្នុងលក្ខណៈជាកណ្ដាល ជាមធ្យម និងបែបជា**សម្មា** ដំណើរជីវិតនោះក៏នឹងមានសេចក្ដីសុខផុតពីទុក្ខបាន។ បើអង្គទាំង៨នេះប្រព្រឹត្តទៅក្នុងលក្ខណៈជ្រុលទៅម្ខាងៗពេក(**អន្តធម៌**) និងបែបជា**អកុសល ជាអវិជ្ជមាន(មិច្ឆា)** ដំណើរជីវិតនោះ*

កំនឹងមានតែសេចក្តីទុក្ខ ប្រាសចាកពីសេចក្តីសុខដែរ។

**អដ្ឋង្គិកមគ្គ**

ដូច្នេះ មជ្ឈិមាបដិបទាដែលមានលក្ខណៈជា **សម្មា** នេះ គឺជាបណ្តូលនៃការត្រាស់ដឹងរបស់ព្រះពុទ្ធ និងជាគ្រឿងសម្គាល់ថាជា **ពុទ្ធ** ដូចមានពុទ្ធដិកានៅក្នុងធម្មចក្កប្បវត្តនសូត្រថាៈ «ម្នាលភិក្ខុទាំងឡាយ **មជ្ឈិមាបដិបទាដែលតថាគតបានត្រាស់ដឹងហើយ** ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ តែងប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ចៈ ដើម្បីត្រាស់ដឹងអរិយសច្ចៈ ដើម្បីនិព្វាន។ មជ្ឈិមាបដិបទានោះ គឺអរិយមគ្គប្រកបដោយអង្គ៨(**អរិយោ អដ្ឋង្គិកោមគ្គោ**) នេះឯង។»

១. **សម្មាទិដ្ឋិៈ** យល់ឃើញត្រូវក្នុងបញ្ហាជីវិត និងចេះដោះស្រាយបញ្ហាទាំងនោះបានត្រឹមត្រូវ ទៅតាមធម្មជាតិរបស់បញ្ហា។

២. **សម្មាសង្កប្បៈ** គិតត្រូវក្នុងបញ្ហាជីវិត គឺគិតក្នុងការចាកចេញពីសេចក្តីប្រាថ្នាលាមកទាំងពួង ការគិតដែលមិនប្រាថ្នាព្យាបាទអ្នកដទៃ និងការគិតដែលគ្មានភាពហិង្សា។

៣. **សម្មាវាចាៈ** ការនិយាយចរចាដែលត្រឹមត្រូវ គឺការនិយាយតែពាក្យពិត ការនិយាយដែលនាំឲ្យអោយកើតការរួបរួម កើតសាមគ្គី ការនិយាយដែលប្រកបដោយភាពទន់ភ្លន់ ផ្អែមល្ហែម និងការនិយាយដែលមានហេតុផលល្អ មានសារៈប្រយោជន៍ទៅតាមពេលវេលានិងកាលៈទេសៈ។

៤. **សម្មាកម្មន្តៈ** ការប្រព្រឹត្តដែលត្រឹមត្រូវ គឺមានមេត្តាករុណា ចេះជួយសង្គ្រោះគ្នា មិនបៀតបៀនដល់អាយុអ្នកដទៃ ចេះគោរពកម្មសិទ្ធិក្នុងទ្រព្យអ្នកដទៃ មិនលួចកេងប្រវ័ញ្ច និងមិនល្មើសប្រវេណីខាងគេទ

ពោលគឺមិនប្រព្រឹត្តខុសក្នុងកាម។

៥. **សម្មាអាជីវៈ** ចិញ្ចឹមជីវិតត្រឹមត្រូវ និងលះបង់ការចិញ្ចឹមជីវិតបែបមិច្ឆាជីព គឺមិនប្រកបអាជីវកម្មលក់ដូរគ្រឿងអាវុធប្រហារ លក់ដូរមនុស្ស លក់ដូរសត្វមានជីវិត លក់ដូរគ្រឿងស្រវឹង និងគ្រឿងញៀន ជាដើម។

៦. **សម្មាវាយាមៈ** ព្យាយាមត្រូវ គឺព្យាយាមមិនឲ្យអកុសលធម៌កើតឡើង ព្យាយាមលះបង់អកុសលធម៌ដែលកើតមកហើយឲ្យអស់ទៅ ព្យាយាមធ្វើអំពើជាកុសលថ្មីៗឲ្យកើតឡើង និងព្យាយាមរក្សាកុសលកម្មនោះឲ្យបានគង់វង្សនិងចំរើនឡើង។

៧. **សម្មាសតិៈ** មានសតិរលឹកឃើញត្រូវ គឺជាការតាំងសតិពិចារណាលើជីវិតថា ជីវិតនេះ គ្រាន់តែជាការរួមផ្សំរបស់រូប វេទនា ចិត្ត និងធម៌ដែលមានលក្ខណៈមិនមែនជាសត្វមិនមែនជាបុគ្គល មិនមែនជាគេឬជាយើងឡើយ។

៨. **សម្មាសមាធិៈ** តម្កល់ចិត្តត្រូវ គឺចិត្តដែលមានការត្រិះរិះ មានការពិចារណា មានការរីករាយ មានសេចក្ដីសុខ មានឧបេក្ខា និងចិត្តដែលមានលក្ខណៈជាឯកគ្គតា គឺនៅនឹងតែមួយកន្លែង។

ក្នុងគម្ពីរវិមុត្តិមគ្គបានបរិយាយអរិយសច្ចៈ៤ថា៖ សម្មាទិដ្ឋិបានដល់ការយល់ត្រូវក្នុងអរិយសច្ចៈ៤។ សម្មាសង្កប្បៈបានដល់ការត្រិះរិះដែលជាកុសល៣ប្រការ។ សម្មាវាចាគឺការមិនពោលពាក្យដែលជាវចីទុច្ចរិត៤ប្រការ។ សម្មាកម្មន្តៈគឺការវៀរចាកកាយទុច្ចរិត៣ប្រការ។ សម្មាអាជីវៈគឺការវៀរចាកមិច្ឆាអាជីវៈ។ សម្មាវាយាមៈបានដល់ការព្យាយាមត្រូវ៤ប្រការ។ សម្មាសតិគឺសតិបដ្ឋាន៤ប្រការ។ សម្មាសមាធិគឺឈាន៤ប្រការ។ ម្យ៉ាងទៀត ប្រសិនបើបុគ្គលបដិបត្តិនូវអរិយមគ្គហើយបានឃើញច្បាស់នូវនិព្វាន នោះហៅថាសម្មាទិដ្ឋិ។ ជាអ្នកភ្ជាក់ហើយតែក្នុងនិព្វាន ហៅថាសម្មាសង្កប្បៈ។ ជាអ្នកលះបង់ហើយក្នុងវចីទុច្ចរិត ហៅថាសម្មាវាចា។ ជាអ្នកវៀរចាកនូវ

ការប្រព្រឹត្តិអំពើអាក្រក់ដោយកាយ ហៅថាសម្មាកម្មន្តៈ។ ជាអ្នកឈប់ប្រកបមិច្ឆាអាជីវៈ ហៅថាសម្មាអាជីវៈ។ ជាអ្នកឈប់ហើយនូវការព្យាយាមខុស ហៅថាសម្មាវាយាមៈ។ ជាអ្នករឭកនឹកដល់និព្វានជាអារម្មណ៍ជានិច្ច ហៅថាសម្មាសមាធិ។

អដ្ឋង្គិកមគ្គទាំង៨ អាចសង្ខេបឲ្យមកនៅត្រឹមតែគោលធម៌ធំៗចំនួន៣ ដែលហៅថាការបដិបត្តិ៣យ៉ាង(ត្រៃសិក្ខា) គឺ៖

១) **បញ្ញា** រួមបញ្ចូលដោយ សម្មាទិដ្ឋិ ១ និងសម្មាសង្កប្បៈ ១

២) **សីល** រួមបញ្ចូលដោយ សម្មាវាចា ១ សម្មាកម្មន្តៈ ១ និងសម្មាអាជីវៈ ១

៣) **សមាធិ** រួមបញ្ចូលដោយសម្មាវាយាមៈ ១ សម្មាសតិ ១ និងសម្មាសមាធិ ១

## អរិយសច្ចៈ៤

ត្រង់ពាក្យថា**សច្ចៈទាំងឡាយ** នៅក្នុងប្រយោគ «ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ(**ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ**) សច្ចៈទាំងឡាយក្នុងទីនេះ បានដល់**ចតុរារិយសច្ចៈ** ឬ*អរិយសច្ចៈ៤ប្រការ*។ អរិយសច្ចៈ៤ គឺជាធម្មជាតិ៤យ៉ាងដែលជារបស់ពិតមិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ (**តថានិ អវិតថានិ អនញ្ញថានិ**) បានសេចក្តីថា មានតែអរិយសច្ចៈទាំង៤នេះឯង ដែលអាចរំលត់នូវសេចក្តីទុក្ខបាន បំបាត់នូវបញ្ហាបាន គឺមិនអាចមានអរិយសច្ចៈតែ៣ ឬ



មានដល់ទៅ៥បានទេ គឺមានតែត្រឹម៤ប៉ុណ្ណោះ ហើយបើទោះជាព្រះពុទ្ធពីអតីតកាលក្តី ព្រះពុទ្ធនាបច្ចុប្បន្នក្តី និងព្រះពុទ្ធតទៅអនាគតក្តី ក៏នឹងត្រាស់ដឹងតែអរិយសច្ចៈ៤ ហើយមានតែអរិយសច្ចៈ៤នេះតែប៉ុណ្ណោះ ដែលនឹងអាចឲ្យមនុស្សត្រាស់ដឹងជាព្រះពុទ្ធ និងជាព្រះអរហន្តបាន។

អរិយសច្ចៈ គឺជាឧបាយ(**សច្ចឧបាយ**) ជារូបមន្តនៃការដោះស្រាយបញ្ហាជីវិត ជាវិធីដើម្បីរំលត់នូវសេចក្តីទុក្ខ ជាឧបករណ៍ដែលនាំទៅរកសេចក្តីសុខ ដែលមានលក្ខណៈជាវិទ្យាសាស្ត្រ មានហេតុផលច្បាស់លាស់ មិនបាច់មានការអង្វរសូមការប្រោសប្រណី ឬសុំជំនួយពីអាទិទេពណាឡើយ គឺអ្នកណាធ្វើហេតុ អ្នកនោះនឹងទទួលបាននូវផល។

អរិយសច្ចៈ៤ប្រការនេះ មានដូចខាងក្រោម៖

១. **ទុក្ខអរិយសច្ចៈ** ការទទួលស្គាល់ថា សច្ចភាពរបស់ជីវិតគឺជាការដែលជីវិតនេះមានសេចក្តីទុក្ខ មានបញ្ហា តាំងពីកើតដល់ស្លាប់ គឺទាំងសេចក្តីទុក្ខខាងផ្លូវកាយ និងសេចក្តីទុក្ខខាងផ្លូវចិត្ត ពោលគឺ**មានរូបមានទុក្ខ មានជីវិតមានបញ្ហា** មានការលំបាក ប្រកបដោយទំនាស់ គ្មានស្ថិរភាព មិនអាចបង្គាប់ឲ្យស្ថិតនៅក្រោមការបញ្ជារបស់យើងបានថាមិនឲ្យកើតទុក្ខ ឬគ្មានបញ្ហាបានឡើយ។

២. **ទុក្ខសមុទយអរិយសច្ចៈ** ការដឹងថា បញ្ហាឬសេចក្តីទុក្ខរបស់ជីវិតនេះ មិនមែនកើតឡើងដោយចៃដន្យទេ តែកើតឡើងព្រោះ**មានហេតុនិងបច្ច័យជាតួបង្កនិងទ្រទ្រង់(ទុក្ខសមុទ័យ)។ ហេតុ** ដែលនាំឲ្យកើតទុក្ខនេះ ព្រះពុទ្ធអង្គទ្រង់ហៅថា **តណ្ហា** ប្រែថាសេចក្តីប្រាថ្នា ឬចំណង់។ **សមុទ័យរបស់ទុក្ខ** ឬ **តណ្ហា** នេះមាន៣ប្រភេទគឺ៖

២.១- **ការចង់បាននូវវត្ថុ**ទាំងឡាយ ដើម្បីបំរើឲ្យដល់ភាពត្រេកអរត្រអាលនៃភ្នែក ត្រចៀក ច្រមុះ អណ្តាត រាងកាយ និងចិត្ត ហៅថា **កាមតណ្ហា** ប្រែថា **សេចក្តីប្រាថ្នាក្នុងកាម**។

២.២- សេចក្តីប្រាថ្នាណាដែលមានលក្ខណៈជា **ចង់កើតទៅជា ចង់ក្លាយទៅជា ចង់បង្កើត**សភាពបែបនេះសភាពបែបនោះ ដូចជាចង់កើតទៅជាទេវតា ចង់ក្លាយទៅជាសេដ្ឋី ចង់ទៅជាជីវិតអមតៈ ចង់មានមុខមាត់កេរ្តិ៍ឈ្មោះយសសក្តិ៍ ឋានៈក្នុងសង្គម ចង់ធ្វើឲ្យជីវិតសង្គមមានភាពស្ថិតស្ថេរមិនប្រែប្រួល ជាដើមនេះហៅថា**ភវតណ្ហា** ប្រែថា **សេចក្តីប្រាថ្នាក្នុងភព។**

៣.៣ សេចក្តីប្រាថ្នាណាមួយដែលមានលក្ខណៈ **ចង់ឈប់-ចង់កើតទៅជា ចង់លែង-ចង់ក្លាយទៅជា ចង់ធុញទ្រាន់នឹងភពដែលកំពុងជួបប្រទះ** ដូចជាធុញទ្រាន់នឿយណាយនឹងជីវិតនេះ លែងចង់រស់ ធុញទ្រាន់នឹងសង្គម ចង់តែបំផ្លាញឲ្យខ្ទេចខ្ទី ជាដើមនេះ ហៅថា **វិភវតណ្ហា** ប្រែថា **សេចក្តីប្រាថ្នាប្រាសចាកភព។**

៣. **ទុក្ខនិរោធអរិយសច្ចៈ** សេចក្តីទុក្ខនិងបញ្ហាទាំងពួង គឺជាសភាវៈដែលអាចកំចាត់បាន និងជាក្តីសង្ឃឹមរបស់ជីវិតមនុស្ស។ ទុក្ខនិរោធ គឺជាសភាវៈប្រាសចាកទុក្ខ និងជាវេវចនស័ព្ទនឹងពាក្យថា **និព្វាន** ឬ **សន្តិ** ដែលជាគោលដៅរបស់មនុសគ្រប់រូប។

៤. **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ** ដើម្បីរំលត់នូវសេចក្តីទុក្ខទាំងអស់នោះ គេត្រូវអនុវត្តតាមយុទ្ធវិធីរំលត់ទុក្ខដែលព្រះសម្មាសម្ពុទ្ធទ្រង់បានរកឃើញ និងអនុវត្តបានផលរួចមកហើយ។ យុទ្ធវិធីនេះមានឈ្មោះថា**អដ្ឋង្គិកមគ្គ** ឬវិធីរំលត់ទុក្ខដែលមានអង្គ៨ ដែលបានពោលរួចមកហើយ ពីខាងលើ។

គម្ពីរវិមុត្តិមគ្គបានបរិយាយថាៈ «ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង(បង្រៀន)ទុក្ខសច្ចៈនេះជាប្រការដំបូង ព្រោះហេតុថា សេចក្តីទុក្ខនេះជារបស់គួរឲ្យខ្ពើមរអើម និងព្រោះអាចយល់បានដោយងាយនៅក្នុងលោកនេះ។ ព្រះអង្គសម្តែងសមុទយសច្ចៈ

ជាប្រការបន្ទាប់ ព្រោះថាការរលត់នូវសមុទយៈ គឺការរលត់នូវទុក្ខ។ បន្ទាប់មកទៀត ព្រះអង្គសម្ដែងនិរោធសច្ចៈ ក្នុងគោលបំណងដើម្បីបញ្ចប់សេចក្ដីទុក្ខដោយគ្មានសល់។ ជាចុងបញ្ចប់នៃការសម្ដែង គឺមគ្គ។ វិធីដែលព្រះអង្គបង្រៀនអរិយសច្ចៈនេះ មានលក្ខណៈដូចគ្នាទៅនឹងវិធីសាស្ត្ររបស់គ្រូពេទ្យដែលឆ្លាតដូច្នោះដែរ ដែលជាដំបូង គ្រូពេទ្យនោះត្រូវត្រួតពិនិត្យសមុដ្ឋាន(រោគសញ្ញា)របស់រោគជាមុនសិន។ បន្ទាប់មក ទើបត្រួតពិនិត្យរកសាហេតុដែលធ្វើឲ្យកើតរោគ។ ដើម្បីកំចាត់ជំងឺនោះ គ្រូពេទ្យក៏ប្រើថ្នាំទៅតាមលក្ខណៈរបស់ជម្ងឺនោះ។ ក្នុងទីនេះ **ជម្ងឺប្រៀបបានដូចជាទុក្ខសច្ចៈ ហេតុនិងបច្ច័យរបស់ជម្ងឺ ជាសមុទយសច្ចៈ។ ការបញ្ចប់នៃជម្ងឺ(ការជាសះស្បើយ)គឺជានិរោធសច្ចៈ ហើយថ្នាំព្យាបាលគឺជា មគ្គសច្ចៈ។**

## និព្វាន

ដូចបានជំរាបពីខាងលើរួចមកហើយថា ពាក្យថា**ពោធិ** ឬ«ការត្រាស់ដឹង» នេះ មានន័យច្រើនយ៉ាង ដូចជាមានន័យថា«**មគ្គ**» មានន័យថា«**សព្វញ្ញុតញ្ញាណ**» មានន័យថា«**ព្រះនិព្វាន**» ជាដើម។ ចំពោះពាក្យថា**មគ្គ** និង**សព្វញ្ញុតញ្ញាណ** បានពន្យល់មកខ្លះហើយ ដូច្នេះខ្ញុំសូមអធិប្បាយ បន្តិចអំពីពាក្យថាការត្រាស់ដឹង ក្នុងន័យជានិព្វាន។

ពាក្យថានិព្វាន មកពីពាក្យថា និ+វាន។ និប្រែថា មិនមាន ឬប្រាសចាក។ វាន ប្រែថាព្រៃ។ ជាន័យធម្មតា និព្វានប្រែថា មិនមានព្រៃ ឬប្រាសចាកព្រៃ ផុតពីព្រៃ។ តែក្នុងន័យធម៌ ពាក្យថាព្រៃ បានដល់ រាគៈ ទោសៈ មោហៈ។ ដូច្នេះ និព្វាន គឺសភាវៈចិត្តដែលមិនមានព្រៃរាគៈ ព្រៃទោសៈ ព្រៃមោហៈ នៅក្នុងខន្ធសន្តាន។

ព្រះអនុរុទ្ធាចារ្យ ដែលតែងគម្ពីរបរមត្ថជោតិកៈ បានពិពណ៌នាអំពីនិព្វាន ដូច្នេះ៖ «**បទមច្ចុត មច្ចន្តំ អសង្ខតមនុត្តរំ និព្វានមិតិ ភាសន្តិ វានមុត្តា មហេសយោ**» ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយដែលជាអ្នកស្វែងរកនូវគុណដ៏ធំ គឺសីល

ខ័ន្ធ សមាធិខ័ន្ធ បញ្ញាខ័ន្ធ ជាអ្នករួចផុតហើយពីតណ្ហាដែលជាគ្រឿងជំពាក់ ព្រះអង្គ រមែងពោលថា មានសភាវធម៌ម្យ៉ាងដែលអាចចូលដល់បាន មាននៅដោយចំពោះ មិនជាប់ដោយសង្ខតធម៌ មិនមានសេចក្ដីស្លាប់ កន្លងផុតហើយពីខន្ធ៥ មិនមានការតាក់តែងដោយបច្ច័យ៤ ជាធម៌ដ៏ប្រសើរបំផុត យ៉ាងណាទីមួយនោះ ជា **និព្វាន**។

នៅមានសេចក្ដីពន្យល់ ឬប្រៀបធៀបដើម្បីឲ្យបានយល់ពីពាក្យថានិព្វានជាច្រើនទៀត ព្រោះថាពាក្យ **និព្វាន** នេះ មិនអាចនឹងយល់បានងាយដោយភាសានិយាយបានទេ អ្នកដែលអាចយល់បានពីនិព្វានបានដោយល្អនិងងាយនោះ គឺមានតែអ្នកដែលបានត្រាស់ដឹងនូវនិព្វាននោះដោយខ្លួនឯង ឬជាអ្នកបានត្រាស់ដឹងនូវពុទ្ធភាវៈ។ សេចក្ដីពន្យល់ឬប្រៀបធៀបដើម្បីឲ្យបានយល់ពីពាក្យថានិព្វាន នោះមានដូចជា៖ **អកុប្បតៈ** ភាវៈដែលមិនកំរើករញ្ជួយ មានសុវត្ថិភាព **អច្ចុតៈ** មិនអាចរំកិលបាន នៅជាប់ជានិច្ច ជារហូត **អនាយាសៈ** រួចផុតពីបញ្ហា ពីសេចក្ដីសោកសៅ **អនារម្ភៈ** ដែលប្រាសចាកនូវភាពចលាចលនិងការវិវាទ **អន្តៈ** ចប់ ទីបញ្ចប់ **អមតៈ** អម្រឹត មិនចេះស្លាប់ **អរហត្ត** ឆ្ងាយចាកកិលេស **អវិវាទៈ** គ្មានវិវាទការឈ្លោះគ្នា **អព្យាបជ្ឈា** រួចពីសេចក្ដីទុក្ខកង្វល់ **អសំហីរៈ** មិនអាចរំកិលបាន មិនអាចយកឈ្នះបាន មិនអាចបដិសេធបាន **អសំកុប្បៈ** មិនកំរើក មិនអាចរំកិលបាន និងមានសុវត្ថិភាព **អានណ្យៈ** រួចផុតពីបំណុល **អបវគ្គៈ** ពេញបរិបូណ៌ ចប់ **អចារៈ** មិនមានជាតិមុខទៀត **ឧត្តមធម៌** ធម៌ដ៏ឧត្តម **ឧបសមៈ** ស្ងប់ស្ងាត់ ធូរស្រាល ស្រាកស្រាន្ត **អនុបាទាយៈ** មិនបន្ថែមទៀត **ខេមៈ** ពេញដោយសន្តិ សុវត្ថិភាព ស្ងប់ មិនកំរើករញ្ជួយ **និព្ភយៈ** ទីដែលគ្មានភ័យ **សុគតិ** កន្លែងសុខ **អចលៈ** មិនមានចលនា មិនកំរើក **អច្ចុត្តៈ** មិនផ្លាស់ប្ដូរ មិនបាត់បង់ **អជរា** មិនចាស់ជរា **បដិនិស្សគ្គោ** ការលះបោល **បរមៈ** ល្អបំផុត **បារៈ** ច្រាំងម្ខាងទៀត **តណ្ហាក្ខយោ** ការអស់ទៅនូវតណ្ហា **វិរាគោ** គ្មានរាគៈ **និរោធៈ** រលត់ **នេក្ខមៈ** ប្រាសចាកនូវរាគៈ **វិមុត្តិ** រួចផុត **បរិយោសាន** ទីបញ្ចប់ **តថតា** យ៉ាងដូច្នោះឯង សច្ចៈ **ឧបាទានក្ខយៈ** ការអស់

*ទៅនូវការប្រកាន់ខ្ជាប់* **និច្ចះ** *ទៀងទាត់* **តិណ្ណះ** *ត្រើយខាងនាយ* **ទន្តភូមិ** *ភូមិសុវត្ថិភាព* **លេណា** *ទីកំបាំងភ័យ កន្ទែងពួន រួបផុត* **វិរជ** *គ្មានធូលី* **អសោកំ** *គ្មានការសោកសៅ* **វិវដ្ដ** *មិនមានវដ្ដ* **វិសង្ខារ** *ប្រាសចាកការតាក់តែង* **សន្តះ** *សេចក្តីស្ងប់* **សប្បាយះ** *សេចក្ដីសប្បាយ* **សុញ្ញតា** *សូន្យ ទទេ* **ចាគោ** *ការលះបង់នូវតណ្ហា* **អនាលយោ** *ការមិនមានអាល័យក្នុងតណ្ហា ។ល។*

## ធ្វើដូចម្តេចទើបបានដល់ ពុទ្ធភាវះ

*ដើម្បីបានដល់ភាវៈជាពុទ្ធ បុគ្គលម្នាក់ៗត្រូវបំពេញនូវសេចក្តីល្អចំនួន១០ យ៉ាង តិចច្រើន និងយូរឆាប់ ទៅតាមប្រភេទនៃពុទ្ធភាវៈ។ បុគ្គលដែលព្យាយាមបំពេញនូវសេចក្តីល្អទាំង១០ដើម្បីសម្រេចនូវពុទ្ធភាវៈនេះ មានឈ្មោះថា* **ពោធិសត្វ** (**ពោធិសត្ត**)*។ ពោធិសត្វមាន៣ប្រភេទគឺះ*

**១-** **សម្មាសម្ពោធិសត្ត** *គឺពោធិសត្វដែលមានបំណងសម្រេចនូវពុទ្ធភាវៈ ក្នុងឋានៈជា* **សម្មាសម្ពុទ្ធ** *គឺបានត្រាស់បានជាព្រះពុទ្ធដោយខ្លួនឯងផង បង្រៀនជនដទៃឲ្យបានសម្រេចនូវពុទ្ធភាវៈផង។ ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ សម្មាសម្ពោធិសត្វ ត្រូវបំពេញបារមីទាំង១០ ក្នុងរយៈពេលពី៤អសង្ខេយ្យ ដល់ ១៦ អសង្ខេយ្យ។*

**២-** **បច្ចេកពោធិសត្ត** *គឺពោធិសត្វដែលមានបំណងសម្រេចនូវពុទ្ធភាវៈក្នុងឋានៈជា* **បច្ចេកពុទ្ធ** *គឺ បានត្រាស់ជាព្រះពុទ្ធដោយខ្លួនឯង តែមិនបានបង្រៀនជនដទៃឲ្យបានសម្រេចនូវពុទ្ធភាវៈទេ។ ដើម្បីបានត្រាស់ជាព្រះបច្ចេកពុទ្ធ បច្ចេកពោធិសត្វត្រូវបំពេញបារមីទាំង១០ ក្នុងរយៈពេលពី ២អសង្ខេយ្យ ដល់ ៣ អសង្ខេយ្យ។*

**៣-** **សាវកពោធិសត្ត** *គឺពោធិសត្វដែលមានបំណងសម្រេចនូវពុទ្ធភាវៈដែរ តែ*

ត្រូវអាស្រ័យការរៀនប្រដៅអំពីព្រះសម្មាសម្ពុទ្ធ និងធ្វើជាសាវ័ក(អ្នកដើរតាម) ជួយព្រះសម្មាសម្ពុទ្ធបង្រៀនអំពីការត្រាស់ដឹងនោះដល់ជនដទៃ។ ដើម្បីបានត្រាស់ជាពុទ្ធសាវ័ក សាវ័កពោធិសត្វត្រូវបំពេញបារមីទាំង១០ ក្នុងរយៈពេលពី១០០កប្ប ដល់ ១អសង្ខេយ្យ។

សេចក្តីល្អចំនួន១០យ៉ាងនោះ ភាសាបាលីហៅថា **បារមី១០**។ **បារមី** ប្រែថា ការរក្សាគុណឲ្យចម្រើនឡើង ការពេញប្រៀប ការធ្វើគុណឲ្យពេញលេញ។ បានសេចក្តីថា ដើម្បីបានសម្រេចនូវពុទ្ធភាវៈ បុគ្គលម្នាក់ៗត្រូវរក្សា(រស់នៅក្នុង) គុណធម៌១០យ៉ាង ត្រូវបំពេញគុណធម៌១០យ៉ាងឲ្យបានពេញ ត្រូវមានគុណធម៌១០យ៉ាងពេញបរិបូណ៌ ពោលគឺមានវិថីជីវិតតាមគុណធម៌ទាំង១០យ៉ាងនេះ។ គុណធម៌ដែលត្រូវបំពេញទាំង១០យ៉ាងនោះ មាន៖

**១- ទានបារមី** គឺការបំពេញគុណធម៌ ដោយការឲ្យ ដែលមាន៤ប្រភេទគឺ

- ការឲ្យឬផ្តល់សម្ភារៈផ្សេងៗ ដើម្បីសម្រាលឬរំដោះទុក្ខអ្នកដទៃ(បច្ច័យ៤) មានចំណីអាហារ ទីលំនៅ សម្លៀកបំពាក់ ថ្នាំព្យាបាល និងផ្សេងៗទៀត ហៅថា «**សង្គហទាន**» ។
- ការអប់រំ ណែនាំអ្នកដទៃឲ្យចេះប្រកបវិជ្ជាជីវៈ ដោយសម្មាអាជីវោ(វិជ្ជាជីវៈត្រឹមត្រូវ) ដើរតាមគន្លងសុចរិតធម៌ដោយការសម្តែងធម៌ទេសនា បង្រៀនសីលធម៌ សុជីវធម៌ផ្សេងៗ ជាពន្លឺចង្អុលបង្ហាញផ្លូវទៅរកសុភមង្គលក្នុងកុសលធម៌ ហៅថា «**ធម្មទាន**» ។
- ការអនុគ្រោះ មិនខឹងគុំកួនតបតនឹងអ្នកប្រព្រឹត្តកំហុសលើយើង និងការលើកលែងទោស ឬផ្តល់សេរីភាពដល់មនុស្ស ឬសត្វដែលពុំមានសេរីភាព ដូចជាការដោះលែងអ្នកទោស ឈ្លើយសង្គ្រាម ទាសករ អ្នកជំពាក់បំណុល និងលើកលែងទោសកំហុសរបស់សត្រូវជាដើម ហៅថា«**អភ័យទាន**» ។
- ការឲ្យ ឬប្រគេន ដែលពុទ្ធវិស័យតែងប្រគេនចំពោះព្រះសង្ឃ អ្នកមានសីល

និងអ្នកមានគុណធម៌ខ្ពស់ ឬទានដែលព្រះពោធិសត្វលោកថ្វាយ ប្រគេនព្រះសម្មាសម្ពុទ្ធឬតាបស នូវបច្ច័យ៤ ហៅថា «**បូជាទាន**» ។

**២- សីលបារមី** គឺការបំពេញគុណធម៌ដោយ«ការតាំងចេតនាថានឹងមិនធ្វើអំពើអាក្រក់ទាំងពួង(ចេតនាសីល)» ដោយ«ការនៅឲ្យឆ្ងាយពីការធ្វើអំពើអាក្រក់និងការកំចាត់នូវអំពើអាក្រក់ទាំងពួង(វេរមណីសីល)» និងដោយ«មិនប្រព្រឹត្តល្មើសទាំងខាងកាយនិងវាចានូវសីលទាំងពួង(អវីតិក្កមសីល)»។ សីលទាំងពួងដែលបុគ្គលតែងមិនប្រព្រឹត្តល្មើសនោះ មាន៤ប្រភេទគឺះ

ក) បទបញ្ញត្តិ ច្បាប់ សីលទាំងឡាយសម្រាប់អ្នកបួសមានសីលសម្រាប់ភិក្ខុនិងភិក្ខុនី(បាដិមោក្ខសំវរសីល) និងបទបញ្ញត្តិច្បាប់ទាំងឡាយសម្រាប់ឧបាសក-ឧបាសិកា បុរស-ស្រ្តីទាំងឡាយមានសីល៥ សីល៨(ឱទាតវសនគហដ្ឋវសីល)។

ខ) បទបញ្ញត្តិ ច្បាប់ សីលទាំងឡាយ ដែលទាក់ទងទៅនឹងការចិញ្ចឹមជីវិតដោយគន្លងធម៌ គឺការចិញ្ចឹមជីវិតដែលមិនទាក់ទងទៅនឹងការជួញដូរគ្រឿងសព្វាវុធ(សត្ថវណិជ្ជា) ការជួញដូរមនុស្ស(សត្តវណិជ្ជា) ការជួញដូរសត្វមានជីវិតសម្រាប់ការបរិភោគ(មំសវណិជ្ជា) ការជួញដូរគ្រឿងស្រវឹងគ្រឿងញៀន(មជ្ជវណិជ្ជា) ការជួញដូរថ្នាំបំពុល(វិសវណិជ្ជា) ការកុហកបោកបញ្ឆោតគេ(កុហនា) ការប្រចុបប្រចែងយកគាប់គួរ(លបនា) ការហុចអំបោះស្រណោះដៃ(នេមិត្តិកតា) ការគាបសង្កត់បំភិតបំភ័យ(និប្បេសិកតា) ការធ្វើសំណូកសូកប៉ាន់(លាភេនលាភំ និជីគីង្សនតា) ជាដើម។

គ) បទបញ្ញត្តិ ច្បាប់ សីលទាំងឡាយដែលទាក់ទងទៅនឹងការប្រើប្រាស់(បរិភាគ)វត្ថុទាំងឡាយ(បច្ច័យ) ដើម្បីចិញ្ចឹមជីវិត ដោយអ្នកប្រើប្រាស់គប្បីពិចារណាថា បច្ច័យដែលទាក់ទងទៅនឹងអាហារ(បិណ្ឌបាត្រ) ទាក់ទងទៅនឹងសម្លៀកបំពាក់(ចីវរ) ទាក់ទងទៅនឹងលំនៅដ្ឋាន(សេនាសនៈ) និងទាក់

ទង៍ទៅនឹងថ្នាំព្យាបាលរោគ(គិលានភេសជ្ជៈ) ទាំងនេះ ត្រូវបរិភោគដោយការមានសតិ ដោយការមិនខ្ជះខ្ជាយ ដោយការជាជារបស់កម្រ មិនបរិភោគជាបែបចោរ(ថេយ្យបរិភោគ) ជាបែបអ្នកជំពាក់គេ(ឥណបរិភោគ) តែដោយការពិចារណាថា បច្ច័យទាំងអស់នេះ បរិភោគប្រើប្រាស់ដើម្បីជាប្រយោជន៍សម្រាប់នាំជីវិតឆ្ពោះទៅរកការមិនមានទុក្ខ ទៅរកការរួចផុតពីកិលេសទៅរកនិព្វាន។

ឃ) បទបញ្ញត្តិ ច្បាប់ សីលទាំងឡាយដែលទាក់ទងទៅនឹងការថែរក្សាចិត្ត ទប់ចិត្ត សំរួមចិត្ត មិនឲ្យធ្លាក់ទៅក្នុងការអូសទាញ ការជម្រុញ ការបើកបររបស់រូបដែលឃើញ(ភ្នែក) សម្លេង ដែលឮ(ត្រចៀក) ក្លិនដែលធុំ(ច្រមុះ) រសជាតិដែលភ្លក្ស(អណ្តាត) វត្ថុដែលប៉ះពាល់(កាយ) និងគំនិតដែលគិតឃើញ(ចិត្ត)។

**៣- នេក្ខម្មៈបារមី** គឺ ការបំពេញសេចក្តីល្អដោយការលះបង់ទ្រព្យសម្បត្តិ ផ្ទះសម្បែង ប្រពន្ធកូន មាតាបិតា ដើម្បីទៅបួសជាបព្វជិត ជាសមណៈ មិនជាប់ជំពាក់នៅក្នុងកាមទាំងឡាយ ជាអ្នកដើរស្វែងរកនូវអាហារបិណ្ឌបាត្រដោយការសុំនូវទានពីអ្នកដែលមានចិត្តសប្បុរស និងខំព្យាយាម ញ៉ាំងជីវិតរបស់ខ្លួនឲ្យមានសេចក្តីស្ងប់ខាងផ្លូវចិត្ត។ ការចេញបួសនេះ អាចចេញបួសជាភិក្ខុ ភិក្ខុណី សាមណេរ សាមណេរី ជាតាជី ជាដូនជី ជាតាបសឫសី ដែលភាវនាធម៌ក្នុងព្រៃជាដើម។ ម្យ៉ាងទៀត នេក្ខម្មៈគឺការវៀរចាកកាម ជាវិវេក ជាឥស្សរភាពផុតពីនីវរណធម៌ទាំងឡាយ ជាសេចក្តីសុខ ជាការលាងគ្រឿងស្មោកគ្រោកចេញពីចិត្ត។

**៤. បញ្ញាបារមី** គឺការបំពេញសេចក្តីល្អដោយការបណ្តុះបញ្ញា បង្កើនបញ្ញារហូតដល់ពេញបរិបូណ៌ អាចកំចាត់បាននូវសេចក្តីល្ងង់ខ្លៅ កំចាត់បាននូវអវិជ្ជាដែលជាមូលហេតុនៃសេចក្តីទុក្ខ។ បញ្ញាអាចបណ្តុះបាននិងបង្កើនបាន ដោយ

វិធី៣យ៉ាងគឺៈ

ក) បញ្ញាអាចកើនបាន ដោយការសិក្សា រៀនសូត្រ សាកសួរ ស្តាប់ អំពីអ្នកដែលចេះដែលដឹង ដែលមានបញ្ញាច្រើនជាងខ្លួន(សុតមយបញ្ញា)

ខ) បញ្ញាអាចកើនបាន ដោយយកសុតមយបញ្ញានោះ មកគិត ពិចារណា រកហេតុរកផល មកពិសោធន៍ ដើម្បីឲ្យរឹតតែបានច្បាស់ និងមានភាពពិតប្រាកដច្រើនឡើង(ចិន្តមយបញ្ញា)

គ) បញ្ញាអាចកើនបាន ដោយការធ្វើចិត្តរបស់ខ្លួនឲ្យមានសេចក្តីស្ងប់ និងកាន់តែស្ងប់ទៅៗ ឧបមាដូចជាទឹកដែលមានកករ នៅពេលដែលយកមកដាក់ឲ្យនៅមួយកន្លែងដោយមិនកំរើក និងមិនមានអ្វីមករំខានដែលនាំឲ្យរង្គើ ទឹកដែលល្អក់នោះក៏នឹងរង ដោយកករដែលនៅក្នុងទឹកនោះ ក៏ធ្លាក់ទៅនៅខាងក្រោម ឯទឹកដែលថ្លាក៏នៅដាច់ដោយឡែកខាងលើ។ ចិត្តដែលស្ងប់មានឧបមាដូចជាភាពថ្លារបស់ទឹក ដែលនឹងអាចមើលឃើញនូវអ្វីៗបានយ៉ាងច្បាស់ ទៅតាមសភាពពិតរបស់វត្ថុនោះ ពុំមានអ្វីមកបិទបាំងឡើយ។ សភាពចិត្តរបៀបនេះ ហៅថាចិត្តមានបញ្ញា។

៥. **វិរិយបារមី** គឺការបំពេញសេចក្តីល្អដោយការព្យាយាម ការតស៊ូ ការឧស្សាហ៍ ការមិនខ្ជិលច្រអូស ក្នុងការធ្វើនូវសេចក្តីល្អ។ សេចក្តីព្យាយាមមាន៤ប្រការ គឺៈ

ក) សេចក្តីព្យាយាមក្នុងកិច្ចការពារមិនឲ្យអំពើអាក្រក់ សេចក្តីអាក្រក់ ឥទ្ធិពលអាក្រក់ ចូលមកក្នុងជីវិតរបស់ខ្លួនយើង(សំវរបធាន)

ខ) សេចក្តីព្យាយាមក្នុងការបណ្តេញ ការកំចាត់ ការយកចេញ ការឈប់ធ្វើអំពើអាក្រក់ សេចក្តីអាក្រក់ ឥទ្ធិពលអាក្រក់ទាំងឡាយ ដែលមាននៅក្នុងជីវិតរបស់ខ្លួនហើយនោះ ឲ្យអស់ទៅវិញ ឲ្យចេញផុតពីវិថីជីវិតរបស់ខ្លួនឲ្យអស់(បហានបធាន)។

គ) សេចក្តីព្យាយាមក្នុងការធ្វើសេចក្តីល្អ អំពើល្អ ឥទ្ធិពលល្អ ឲ្យកើតច្រើន

ឡើងៗនៅក្នុងជីវិតរបស់យើង នៅក្នុងវិថីនៃការរស់នៅរបស់ខ្លួន។

ឃ) សេចក្តីព្យាយាមក្នុងការថែរក្សាអំពើល្អ សេចក្តីល្អ ឥទ្ធិពលល្អ ដែលកើតមាននៅក្នុងជីវិតរបស់ខ្លួនយើងហើយនោះ ឲ្យស្ថិតស្ថេរគង់វង្ស មិនឲ្យបាត់បង់ទៅវិញ និងរឹតតែចំរើនឡើងៗ។

៦. **ខន្តិបារមី** គឺការបំពេញសេចក្តីល្អដោយការអត់ធន់ អត់ធ្មត់។ តាមតួអក្សរនៃភាសាបាលី ខន្តីប្រែថា ការអត់ធន់ ឬប្រែថា ការសមគួរនឹងទទួលផល។ គឺបើអត់ធន់បានកាន់តែច្រើនកាលណា ផលក៏នឹងទទួលបានកាន់តែច្រើនប៉ុណ្ណោះដែរ។ អត់ គឺទប់ បានដល់ហាមចិត្តមិនឲ្យធ្វើអ្វីតាមតែចិត្តចង់។ ធន់ គឺទ្រាំចំពោះអារម្មណ៍ដែលខ្លួនមិនចូលចិត្ត ដែលខ្លួនស្អប់ កាលណាអារម្មណ៍នោះចូលមកប៉ះទង្គិចផ្លូវចិត្ត យើងក៏ធន់ ដើម្បីប្រកាន់នៅក្នុងសេចក្តីល្អរបស់យើង។

៧. **សច្ចបារមី** គឺការបំពេញសេចក្តីល្អ ដោយសច្ចភាព ដោយសេចក្តីពិត។ ពាក្យថាសច្ចៈ បានសេចក្តីថា យ៉ាងនោះឯង(តថតា) មិនទៅជាដទៃទៀត ជាម្យ៉ាងតែប៉ុណ្ណោះ។ សច្ចៈមានបួនប្រភេទគឺ សច្ចវាចា សច្ចញាណ បរមត្ថសច្ចៈ និងអរិយសច្ចៈ។ បុគ្គលពោលពាក្យពិតនិងមិនពោលពាក្យកុហក ហៅថាសច្ចវាចា។ ការពិនិត្យពិច័យនូវអ្វីដែលមិនពិតប្រាកដ ហៅថាសច្ចញាណ។ និព្វានជាបរមត្ថសច្ចៈ។ សច្ចៈដែលបដិបត្តិដោយព្រះអរិយបុគ្គល ហៅថាអរិយសច្ចៈ(អរិយសច្ចៈ៤)។

៨. **អធិដ្ឋានបារមី** គឺការបំពេញសេចក្តីល្អ ដោយការតាំងចិត្តមាំមួនមិនរាករេ។ គឺបើតាំងចិត្តថានឹងធ្វើកិច្ចអ្វីមួយហើយ គឺប្រកាន់ខ្ជាប់ តាំងមាំ ជឿជាក់ថានឹងបានទទួលជោគជ័យជាពិតប្រាកដ មិនរួញរាចំពោះឧបសគ្គដែលមករារាំង និងយកឈ្នះឧបសគ្គនោះជានិច្ច។ អធិដ្ឋានឬការតាំងចិត្តមាន៤យ៉ាងគឺ ការតាំងចិត្តក្នុងសច្ចៈ(សច្ចាធិដ្ឋាន) ការតាំងចិត្តក្នុងការបរិច្ចាគលះបង់(ចាគាធិដ្ឋាន) ការតាំងចិត្តក្នុងសេចក្តីស្ងប់(ឧបសមាធិដ្ឋាន) និងការតាំងចិត្តក្នុងបញ្ញា(បញ្ញាធិដ្ឋាន)។

៩. **មេត្តាបារមី** *គឺការបំពេញសេចក្តីល្អដោយគុណធម៌ «មេត្តា» គឺ ការមានមេត្រីភាព, សេចក្តីរាប់រក, សេចក្តីរាប់អានគ្នា, សេចក្តីប្រណី, បំណងចង់ឲ្យអ្នកដទៃបានសេចក្តីសុខ-ចម្រើនដូចខ្លួនដែរ។ ការពន្យល់ពាក្យថាមេត្តាអាចធ្វើបានដោយសេចក្តីប្រៀបធៀបថាដូចជាមាតាបិតា កាលបើសម្លឹងមើលបុត្រតែមួយរបស់ខ្លួន ក៏កើតនូវចិត្តដែលប្រកបដោយមេត្តានិងសេចក្តីប្រោសប្រណីដល់បុត្រយ៉ាងណា មេត្តាក៏មានលក្ខណៈដូច្នោះឯង។ មេត្តាបារមី គឺការស្រឡាញ់ដល់សត្វទាំងអស់(សត្វតិរច្ឆាន មនុស្ស ទេវតា ព្រហ្ម ប្រេត អសុរកាយ នរក) ដោយគ្មានព្រំដែន ដោយគ្មានការរើសអើង គ្មានសត្រូវ គ្មានសេចក្តីខឹងក្រោធ។*

១០. **ឧបេក្ខាបារមី** *គឺការបំពេញសេចក្តីល្អដោយគុណធម៌ ឧបេក្ខា គឺការដាក់ចិត្តជាកណ្តាល ដំណើរចិត្តដែលមិនលំអៀងទៅខាងណា ដំណើរចិត្តដែលមិនចូលចិត្តទៅខាងណាមួយ ការមិនប្រកាន់ខ្ជាប់ទៅលើអ្វីមួយ អព្យាក្រឹត្យភាព ការបដិបត្តិក្នុងលក្ខណៈជាអ្នកដែលស្មើភាពគ្នា(សមភាព) ការពន្យល់ពាក្យថាឧបេក្ខាអាចធ្វើបានដោយសេចក្តីប្រៀបធៀបថា ដូចជាមាតាបិតាដែលមិនបានយកចិត្តទុកដាក់នឹងកូនណាមួយហួសហេតុពេក តែយកចិត្តទុកដាក់ចំពោះកូនដោយស្មើៗគ្នា ហើយរក្សាចិត្តដែលស្មើៗគ្នានោះចំពោះកូនទាំងឡាយយ៉ាងណា ឧបេក្ខាក៏មានលក្ខណៈដូច្នោះដែរ។*

*ទសបារមីទាំង១០នេះ ទុកដូចជានាវាសម្រាប់នាំបុគ្គល(ពោធិសត្វ) ទៅដល់ត្រើយខាងនាយ ទៅដល់គោលដៅ គឺអមតៈមហានិព្វាន។ ការដែលបានសម្រេចនូវពុទ្ធភាវៈប្រភេទណាមួយនោះ គឺអាស្រ័យទៅតាមការតាំងចិត្ត កំរិតនៃការព្យាយាម និងពេលវេលា។ តែអ្វីដែលជាលទ្ធផលដែលពុទ្ធភាវៈមានដូចៗគ្នានោះ គឺការបានត្រាស់ជាព្រះអរហន្ត គ្មានកិលេសនៅក្នុងខ័ន្ធសន្តានទៀតឡើយ។*

# តើព្រះពុទ្ធលោកបង្រៀនអ្វីខ្លះ

*សំនួរថា តើព្រះពុទ្ធលោកបង្រៀនអ្វីខ្លះ ជាសំនួរដែលមាណពម្នាក់ធ្លាប់បានសួរចំពោះព្រះភិក្ខុមួយរូបក្នុងចំណោមភិក្ខុ៥រូប ដែលជាសិស្សដំបូងរបស់ព្រះសម្មាសម្ពុទ្ធ។ មានសេចក្តីដំណាលនៅក្នុងគម្ពីរព្រះត្រៃបិដកថា នាពេលព្រឹកមួយ ព្រះអរហន្តព្រះនាម**អស្សជិ** បាននិមន្តចេញបិណ្ឌបាត្រនៅក្នុងក្រុងរាជគ្រឹះ។ ពេលនោះមានបរិព្វាជកម្នាក់ឈ្មោះ**សារីបុត្ត** បានឃើញនូវព្រះអស្សជិដ៏មានអាយុកំពុងត្រាច់បិណ្ឌបាត បរិបូណ៌ដោយឥរិយាបថ មានភ្នែកសង្រួមគួរជាទីជ្រះថ្លា ក៏បានពោលពាក្យទៅព្រះអស្សជិថា៖ ម្នាលលោកដ៏មានអាយុ ឥន្ទ្រីយ៍ទាំងឡាយរបស់លោកក៏ស្រស់បស់ សម្បុរស្បែករបស់លោកក៏ស្អាតផូរផង់ ម្នាលលោកដ៏មានអាយុ លោកបួសចំពោះអ្នកណា ម្យ៉ាងទៀតអ្នកណាជាគ្រូរបស់លោក ខ្លួនលោកនេះឯងពេញចិត្តធម៌របស់អ្នកណា..........។ល។.........**ចុះគ្រូរបស់លោកម្ចាស់ ពោលពាក្យដូចម្តេច សម្តែងធម៌ដូចម្តេច**។ គ្រានោះព្រះអស្សជិដ៏មានអាយុបានពោលនូវធម្មបរិយាយដល់បរិព្វាជក ឈ្មោះសារីបុត្ត ថា៖*

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ** ( **អាហ** )
**តេសញ្ច យោ និរោធោ ឯវំវាទី មហាសមណោតិ។**

***«ព្រះមហាសមណៈ មានប្រក្រតីពោលពាក្យយ៉ាងនេះថា «ធម៌ទាំងឡាយណាដែលតែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ហើយព្រះតថាគតពោលនូវសេចក្តីរលត់ និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះ។»***

*គាថាដ៏ល្បីល្បាញនេះ ពុទ្ធបរិស័ទទាំងឡាយតែងតែយកមកប្រាប់ ចារឹកសរសេរ ប្រាប់ដល់ជនទាំងឡាយអំពី **ធម៌** ដែលព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀន។ **ធម៌** ឬដែលយើងតែងហៅថា**ព្រះធម៌** នោះ គឺជាសិក្ខាឬការសិក្សាដែលព្រះពុទ្ធអង្គបានបង្រៀន(សំដែងឬទេសនា) ដល់មហាជនទាំងឡាយដោយផ្ទាល់មាត់អស់រយៈពេល*

៤៥ឆ្នាំ គឺតាំងពីព្រះអង្គបានត្រាស់ដឹងក្នុងព្រះជន្មាយុ៣៥ព្រះវស្សា រហូតដល់ព្រះអង្គចូលបរិនិព្វាន(មរណៈភាព) ក្នុងព្រះជន្មាយុ៨០ព្រះវស្សា។ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀនក្នុងរយៈពេល៤៥ឆ្នាំនេះ មានចំនួនច្រើនណាស់ លោកថាមានចំនួនដល់ទៅ៨៤០០០ ព្រះធម្មក្ខន្ធ ហើយបន្ទាប់ពីព្រះពុទ្ធអង្គចូលបរិនិព្វានទៅសាវ័ករបស់ព្រះអង្គក៏បានរួបរួមនូវព្រះធម៌ទាំងឡាយដែលទ្រង់បានបង្រៀននោះចងក្រង និងចារឹកជាតួអក្សរ ដោយហៅថា **ព្រះត្រៃបិដក** ប្រែថា **ប្រជុំពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ៣ប្រភេទ** ដែលមាន៖

១- **ព្រះវិន័យបិដក** គឺប្រជុំពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលទាក់ទងទៅនឹងរឿងសីល រឿងវិន័យ រឿងច្បាប់ផ្សេងៗ ដែលបរិស័ទទាំងបួនគប្បីអនុវត្តតាម

២- **ព្រះសុត្តន្តបិដក** គឺប្រជុំពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលទាក់ទងទៅនឹងការសម្ដែងធម៌ទេសនា ការបរិយាយធម៌ ការសាកសួរដេញដោលប្រវត្តិសាស្ត្របុគ្គល(ជាតក) វិថីជីវិត ជាដើម។ល។

៣- **ព្រះអភិធម្មបិដក** គឺប្រជុំពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលទាក់ទងទៅនឹងធម៌ដែលជ្រាលជ្រៅ គឺធម៌ដែលទាក់ទងទៅនឹងចិត្ត ចេតសិក រូប និងនិព្វាន គឺមិនមានទាក់ទងទៅនឹងបុគ្គល ហេតុការណ៍ ឬស្ថានទីឡើយ គឺមានលក្ខណៈជាវិជ្ជាសាស្ត្រសុទ្ធសាធ។

ព្រះត្រៃបិដកនេះ មានចារឹកជាភាសាបាលី និងបានប្រែជាភាសាខ្មែរចប់សព្វគ្រប់ហើយ ដោយ**ក្រុមជំនុំព្រះត្រៃបិដកនៃពុទ្ធសាសនបណ្ឌិត្យកម្ពុជា** កាលពីឆ្នាំ១៩៣០ដល់ឆ្នាំ១៩៦៨ មានចំនួនទាំងអស់១១០ក្បាល ដោយក្បាលនីមួយៗមានភាសាបាលីនៅទំព័រខាងឆ្វេង និងមានភាសាខ្មែរនៅទំព័រខាងស្ដាំ ឬបើជាបាលីសុទ្ធនិងភាសាខ្មែរសុទ្ធនោះ គឺមានដល់ទៅចំនួន៥៥ក្បាលដ៏ក្រាស់ៗ។

ជាសង្ខេប គុណរបស់ព្រះធម៌(**ធម្មគុណ**)មាន៦យ៉ាង ជាគុណដែលពុទ្ធបរិស័ទយើងតែងសូត្រនមស្សការរំលឹកនិងលើកតម្កើងជារៀងរាល់ពេលនោះឯងគឺ៖

១. **ធម្មោ** ធម៌ គឺជាផ្លូវ(មគ្គ) ដែលនាំទៅរកការត្រាស់ដឹង និងព្រះនិព្វាន(ផល)

២- **សន្ទិដ្ឋិកោ** ជាមគ្គនិងផល ដែលបុគ្គលម្នាក់ៗត្រូវបដិបត្តិដោយខ្លួនឯង ទើបដឹងច្បាស់ ឃើញច្បាស់ដោយខ្លួនឯង មិនអាចមានអ្នកដទៃធ្វើជំនួសបានទេ

៣- **អកាលិកោ** មិនមានព្រំដែនដោយកាលវេលា គឺបដិបត្តិដោយគ្រប់គ្រាន់ពេលណា ក៏សម្រេចពេលនោះ ឃើញផលពេលនោះ និងជាសច្ចៈយ៉ាងនេះជានិច្ច

៤- **ឯហិបស្សិកោ** អាចចូលមកមើលនិងពិសោធន៍បាន ព្រោះជារបស់ពិត ល្អពិត ធ្វើបានផលពិតៗ

៥ **ឱបនយិកោ** ជាធម៌ដែលគប្បីនាំយកមកទុកក្នុងចិត្ត យកមកបដិបត្តិ យកមកធ្វើជាវិថីជីវិតរបស់បុគ្គលម្នាក់ៗ

៦ **បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ** ជាការបដិបត្តិដែលត្រូវប្រើបញ្ញា ត្រូវមានការសិក្សាឲ្យច្បាស់លាស់ ជារបស់ដែលវិញ្ញូជនចូលចិត្ត។

ដូចបានជំរាបពីខាងលើមកហើយថា ព្រះសម្មាសម្ពុទ្ធជាសព្វញ្ញុតញ្ញាណ គឺព្រះអង្គដឹងសព្វគ្រប់ទាំងអស់ ឯព្រះធម៌ដែលព្រះអង្គយកមកបង្រៀនមានរហូតដល់ទៅ៨៤០០០ព្រះធម្មក្ខន្ធឯណោះ(៥៥ក្បាល) ដែលមើលទៅឃើញថាដូចជាច្រើនណាស់បើប្រៀបទៅនឹងសាសនាដទៃទៀត តែអ្វីដែលព្រះពុទ្ធអង្គយកមកបង្រៀនដល់ពុទ្ធបរិស័ទវិញ គឺមានចំនួនតិចណាស់បើប្រៀបទៅនឹងការត្រាស់ដឹងជាសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ។ ភាសិតដែលព្រះអស្សជិបានប្រាប់ដល់ព្រះសារីបុត្រនោះ គឺជាសេចក្តីសង្ខេបមេរៀនដ៏ខ្លីជាទីបំផុត ដែលព្រះអស្សជិលោកបានរៀនអំពីព្រះពុទ្ធអង្គដោយផ្ទាល់នៅ ពេលដែលព្រះពុទ្ធអង្គបានសម្តែងជាលើកដំបូងបង្អស់ចំពោះអ្នកបួស៥រូបគឺបញ្ចវគ្គីយ៍ភិក្ខុ នៅឯព្រៃឥសីបតនមិគទាយវ័ន ដែលក្នុងនោះមានលោកមួយអង្គផងដែរ។

ម្យ៉ាងទៀត នៅក្នុងព្រះសូត្រដែលមានឈ្មោះថា**សីសបាវនសុត្តំ** ព្រះពុទ្ធ

អង្គបានសម្តែងប្រាប់ដល់ពួកភិក្ខុទាំងឡាយ ដោយធ្វើការប្រៀបធៀបរវាងស្លឹកឈ្ន់ដែលនៅលើដើមដ៏មានចំនួនច្រើន ថាដូចជាការត្រាស់ដឹងរបស់ព្រះអង្គដែរ គឺមានចំនួនច្រើនណាស់(**សព្វញ្ញុតញ្ញាណ ឬ សព្វវិទូ**)។ ឯការត្រាស់ដឹងដែលព្រះអង្គយកមកបង្រៀនដល់ពុទ្ធបរិស័ទនោះ មានចំនួនតែបន្តិចទេ គឺប្រហែលត្រឹមតែចំនួនស្លឹកឈ្ន់ដែលនៅក្នុងព្រះហស្តរបស់ព្រះអង្គតែប៉ុណ្ណោះ ព្រោះថាអ្វីដែលមិនបានប្រយោជន៍ដល់ការរំលត់ទុក្ខ ដើម្បីការត្រាស់ដឹងទេនោះ ព្រះអង្គនឹងមិនបង្រៀនទេ **គឺបង្រៀនតែអ្វីដែលជាទុក្ខ ហេតុជាទីកើតឡើងនៃទុក្ខ សេចក្តីរំលត់ទុក្ខ និងបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ** តែប៉ុណ្ណោះ។ ព្រោះថា ពាក្យនុះប្រកបដោយប្រយោជន៍ ពាក្យនុះជាអាទិព្រហ្មចរិយធម៌ ពាក្យនុះប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន។

ម្យ៉ាងទៀត ព្រះសម្មាសម្ពុទ្ធទ្រង់លើកទឹកចិត្តឲ្យព្រះភិក្ខុសង្ឃផ្សព្វផ្សាយបង្រៀន អនុគ្រោះ ចំពោះមហាជនទាំងឡាយ ដោយការឲ្យមហាជនទាំងឡាយនោះរៀនឲ្យចេះ(មិនចាំបាច់តែជាពុទ្ធបរិស័ទទេ) នូវអរិយសច្ចៈ៤ សម្រាប់យកមកអនុវត្តធ្វើជាវិថីជីវិតរបស់ខ្លួន ដូចមាននៅក្នុងសេចក្តីថា៖

«ម្នាលភិក្ខុទាំងឡាយ (បើ)អ្នកទាំងឡាយគួរអនុគ្រោះចំពោះជនពួកណាមួយ ឬជនជាមិត្តក្តី ជាអាមាត្យក្តី ជាញាតិក្តី ជាសារលោហិតក្តី គប្បីអនុគ្រោះជននោះនូវពាក្យដែលគួរស្តាប់ចុះ ម្នាលភិក្ខុទាំងឡាយ គឺអ្នកទាំងឡាយគួរញុំាងជនទាំងនោះឲ្យសមាទាន ឲ្យតាំងនៅ ឲ្យដំកល់នៅ ក្នុងការត្រាស់ដឹងនូវអរិយសច្ចៈ៤តាមសេចក្តីពិត។ អរិយសច្ចៈ៤គឺអ្វីខ្លះ។ គឺការដឹងទុក្ខ ការដឹងហេតុជាទីកើតឡើងនៃទុក្ខ ការដឹងទីរំលត់ទុក្ខ និងការដឹងបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ។»

ព្រោះថា **អ្នកណាដែលបានដឹងអំពីអរិយសច្ចៈ៤នេះ ទើបអ្នកនោះឈ្មោះថាជាអ្នកប្រកបដោយវិជ្ជា** ដូចមានពុទ្ធវចនៈថា៖ «ម្នាលភិក្ខុទាំងឡាយ ការដឹងទុក្ខ ការ

ដឹងហេតុជាទីកើតឡើងនៃទុក្ខ ការដឹងទីរំលត់ទុក្ខ ការដឹងបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខឯណា ម្នាលភិក្ខុទាំងឡាយ នេះហៅថាវិជ្ជា។ មួយវិញទៀត **បុគ្គលដែលប្រកបដោយវិជ្ជា(វិជ្ជាគតោ)** ក៏រមែងមានដោយហេតុប៉ុណ្ណោះឯង។ **ឯអ្នកដែលមិនដឹងអំពីអរិយសច្ចៈ៤នេះទេ ហៅថា បុគ្គលដែលលុះក្នុងអវិជ្ជា(អវិជ្ជាគតោ)**។»

មជ្ឈិមាបដិបទាក្តី អដ្ឋង្គិកមគ្គក្តី អរិយសច្ចៈ៤ក្តី និព្វានក្តី គឺជាការត្រាស់ដឹងដែលជាគោលរបស់ព្រះសម្មាសម្ពុទ្ធ ដែលខ្ញុំលើកយកមកជំរាបដោយសង្ខេបតែប៉ុណ្ណោះ ព្រោះថា បើប្រៀបធៀបទៅនឹងចំនួនធម៌ដែលមានចំនួនដល់ទៅប្រាំបីម៉ឺនបួនពាន់(៨៤០០០)ព្រះធម្មក្ខន្ធ ហើយបើគិតជាព្រះត្រៃបិដកភាសាបាលី-ខ្មែរដែលមានចំនួនដល់ទៅ១១០ក្បាលនោះ ឃើញថាតិចណាស់ តែបើអាននូវភាសិតរបស់ព្រះសារីបុត្រ ដែលជាអគ្គសាវ័កស្តាំរបស់ព្រះសម្មាសម្ពុទ្ធខាងក្រោមនេះហើយ ប្រាកដជាមានសេចក្តីអស្ចារ្យក្នុងចិត្តជាពុំខាន អំពីសារៈសំខាន់នៃធម៌ជាគោលនៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ។ ព្រះសារីបុត្រ បានមានដីកាចំពោះភិក្ខុដែលនៅក្រោមឱវាទថា៖

«នែអ្នកទាំងឡាយ **ស្នាមជើងទាំងឡាយណាមួយរបស់សត្វដែលនៅលើផ្ទៃផែនដី ស្នាមជើងទាំងអស់នោះតែងប្រជុំចុះ(ដាក់ចូលចុះ)ក្នុងស្នាមជើងសត្វដំរី(បានទាំងអស់)**។ ស្នាមជើងសត្វដំរី ប្រាកដជាវិសេសជាងស្នាមជើងនៃសត្វទាំងអម្បាលនោះ ព្រោះស្នាមជើងដំរីនោះជាស្នាមជើងធំ(ជាងស្នាមជើងនៃសត្វទាំងឡាយ) ដូចម្តេចមិញ ម្នាលអ្នកទាំងឡាយដ៏មានអាយុ **កុសលធម៌ទាំងឡាយណានីមួយ កុសលធម៌ទាំងអស់នោះតែងសង្គ្រោះចូល(ចំណុះឲ្យ) ក្នុងអរិយសច្ចៈទាំង៤ ដូច្នោះឯង**។ អរិយសច្ចទាំង៤តើដូចម្តេចខ្លះ? គឺទុក្ខអរិយសច្ចៈ១ ទុក្ខសមុទយអរិយសច្ចៈ១ ទុក្ខនិរោធអរិយសច្ចៈ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ១»។

# ថ្ងៃប្រសូត្រ

ព្រះសិទ្ធត្ថកុមារ ប្រសូត្រនៅថ្ងៃសុក្រ ១៥កើត ខែវិសាខ ឆ្នាំច មុនព.ស. ៨០ឆ្នាំ នៅក្នុងត្រកូលក្សត្រ នាប្រទេសនេប៉ាលបច្ចុប្បន្ន ឬជម្ពូទ្វីបពីអតីតកាល។ ដូច្នេះ ព្រះអង្គគឺជាកូនមនុស្សម្នាក់។ តែការដែលមនុស្សធម្មតាម្នាក់បានត្រាស់ដឹងនិងក្លាយខ្លួនទៅជាព្រះពុទ្ធ ឬអ្នកប្រាជ្ញនេះ មិនមែនត្រឹមតែបានមានកំណើតជាមនុស្សហើយ ក៏ស្រាប់តែបានក្លាយទៅជាអ្នកប្រាជ្ញឬព្រះពុទ្ធដោយស្វ័យប្រវត្តិ ឬដោយងាយៗនោះទេ តែព្រោះបន្ទាប់ពីកើតហើយ បានទទួលនូវការចិញ្ចឹមបីបាច់ រក្សាការពារពីមាតាបិតានិងញាតិមិត្ត បានទទួលនូវការអប់រំ ការសិក្សាល្អគ្រប់គ្រាន់ និងមានការប្ដេជ្ញាការតាំងចិត្ត ការអធិដ្ឋានដ៏ខ្លាំងក្លានិងរឹងមាំណាស់ ទើបអាចសម្រេចនូវគោលបំណងណានីមួយបាន។ ការសិក្សាអំពីថ្ងៃប្រសូត្ររបស់ព្រះពុទ្ធអង្គ តាមរយៈរូបភាពពុទ្ធប្រវត្តិ នឹងអាចឲ្យយើងបានយល់ច្បាស់អំពីសារៈសំខាន់និងផលប្រយោជន៍នៃការរំលឹកដល់ថ្ងៃប្រសូត្រ នាឱកាស បុណ្យវិសាខបូជានេះបានល្អ។



ខួបប្រសូត្ររបស់ព្រះពុទ្ធ(ព្រះសិទ្ធត្ថ) មានសារៈដែលគួរឲ្យសិក្សានិងយកជាគំរូសំរាប់ការអប់រំដល់កុលបុត្រកុលធីតាគ្រប់រូប មិនថាជាជនជាតិណាទេ។ តាមរយៈពុទ្ធប្រវត្តិ ជាពិសេសតាមរូបគំនូរដែលឆ្លុះបញ្ចាំងពីការប្រសូត្ររបស់ព្រះពុទ្ធនោះ យើងឃើញថា នៅពេលប្រសូត្រចេញអំពីផ្ទៃមាតាភ្លាម ទារកដ៏តូចនោះ បានឈានដើរទៅមុខឆ្ពោះទៅទិសខាងជើងចំនួន៧ជំហាន ដោយមានផ្កាឈូកទ្រពីក្រោម ហើយក៏ឈប់និងលើកចង្អុលដៃឡើងទៅ

*លើ ព្រមទាំងនិយាយថា៖* **អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា មេ ជាតិនត្ថិទានិបុនព្ភ វោ** *ប្រែជាខ្មែរថា៖ ‹‹ខ្លួនយើងជាកំពូលនៃលោក ជាបុគ្គលប្រសើរជាងគេក្នុងលោក ជាចម្បងជាងគេក្នុងលោក ជាតិនេះជាកំណើតចុងក្រោយបំផុតរបស់យើង អំណើះតទៅមុខយើងលែងកើតទៀតហើយ››។*

*អ្វីដែលយើងគួរយកជាលំអានបានអំពីព្រឹត្តិការណ៍នាពេលប្រសូត្រនេះ មាន ៣បំណុចគឺ៖*

ក) *មនុស្សម្នាក់ៗ គប្បីមានគោលដៅ សំរាប់ជីវិតខ្លួនតាំងតែពីនៅតូចៗ ដោយគោលដៅនេះអាចជាគោលដៅដែលគេបង្កើតដោយខ្លួនឯង ឬក៏អាចជាគោលដៅដែលមាតាបិតានិងអាណាព្យាបាលជួយកូន ឱ្យអាចរៀនរៀបចំគោលដៅសំរាប់ជីវិតរបស់ខ្លួនតាំងពីនៅតូចៗ។ ក្នុងពុទ្ធសាសនា* **អធិដ្ឋាន***គឺការតាំងចិត្ត* **ឆន្ទៈ** *គឺសេចក្តីប្រាថ្នា និង***សទ្ធា***គឺការជឿច្បាស់ថាអាចធ្វើបានសុទ្ធតែជាគោលធម៌ដើម្បីសំរេចគោលដៅនាអនាគត។*

ខ) *ដើម្បីសម្រេចនូវគោលបំណងនេះ (ដើម្បីបានត្រាស់ជាព្រះពុទ្ធ) ព្រះកុមារត្រូវប្រើពេលវេលារហូតដល់ទៅ៣៥ឆ្នាំ ដោយឆ្លងកាត់នូវវិធីជាច្រើនទំរាំនឹងសម្រេច។ ជំហានទាំង៧របស់ព្រះកុមារ នៅក្នុងពុទ្ធប្រវត្តិ គឺជាអត្ថប្បដិរូបរបស់វិធីដែលនាំទៅរកការសម្រេចគោលបំណងនិងការត្រាស់ដឹង។ ជំហានទាំង៧នេះ ព្រះពុទ្ធអង្គទ្រង់ហៅថា***ពោជ្ឈង្គៈ៧** *ដែលប្រែថា អង្គ៧យ៉ាងដែលនាំឱ្យបានត្រាស់ដឹង ដែលមាតាបិតាអាចយកមកធ្វើជាមាត្រដ្ឋានក្នុងការអប់រំបុត្រធីតារបស់ខ្លួនតាំងពីតូចៗ និងបណ្តុះឱ្យកូនយកអង្គទាំង៧នេះ ធ្វើជាមាត្រដ្ឋានក្នុងការស្វែងរកចំណេះវិជ្ជា។ ពោជ្ឈង្គៈ៧ ឬអង្គដែលនាំឱ្យបានត្រាស់ដឹង ឬអង្គដែលនាំឱ្យសំរេចនូវគោលដៅ នោះ មាន៖*

១. **សត** *ការអប់រំកូន និងអប់រំចិត្តឱ្យមានសតិគឺការរលឹកបានល្អជានិច្ច ចំពោះគោលដៅ។*

២. **ធម្មវិចយ** *ការអប់រំកូននិងអប់រំចិត្ត ឱ្យពេញចិត្តនៅក្នុងការស្រាវជ្រាវ ពិនិត្យពិច័យ វិភាគចំពោះគោលដៅ វិភាគលើធម្មៈឬអ្វីៗទាំងពួងដោយមិនចេះតែជឿ ឬបណ្ដោយទៅតាមយថាកម្ម។*

៣. **វិរិយៈ** *ការអប់រំកូននិងអប់រំចិត្ត ឱ្យមានសេចក្ដីព្យាយាម ឧស្សាហ៍ អត់ធន់ អត់ធ្មត់ជានិច្ចចំពោះការងារដើម្បីសំរេចគោលដៅ។*

៤. **បីត** *ការអប់រំកូននិងអប់រំចិត្ត ឱ្យមានសេចក្ដីរីករាយជានិច្ច។*

៥. **បស្សទ្ធិ** *ការអប់រំកូននិងអប់រំចិត្ត ឱ្យមានចិត្តតាំងមាំជានិច្ចចំពោះការងារដើម្បីសំរេចគោលដៅ។*

៦. **សមាធិ** *ការអប់រំកូននិងអប់រំចិត្ត ឱ្យមានសេចក្ដីស្ងប់ជានិច្ចចំពោះការងារដើម្បីសំរេចគោលដៅ។*

៧. **ឧបេក្ខា** *ការអប់រំកូននិងអប់រំចិត្ត ឱ្យមានចិត្តជាកណ្ដាល ចិត្តជាយុត្តិធម៌ចំពោះការងារដើម្បីសំរេចគោលដៅ។*

គ) *ផ្កាឈូកដែលមកទ្រព្រះកុមារ គឺជាការឆ្លុះបញ្ចាំងមួយទៀតអំពីពុទ្ធប្រវត្តិដោយរូបភាពនេះ។ ផ្កាឈូកក្នុងភាសាបាលី គឺ***បទុម** *ឬ***កមល**។ *ក្នុងនេះដែរ* **កមល** *នេះក៏បានន័យដល់***បេះដូង** *របស់មនុស្សយើងនេះដែរ។ ការដែលមានផ្កាឈូក ឬកមល ឬបេះដូងមកទ្របាទជើងនេះ អាចបានន័យដល់ការដែលមាតាបិតាឬអាណាព្យាបាល គប្បីផ្ដល់នូវការស្រឡាញ់ ការគាំទ្រ ការឧបត្ថម្ភការជ្រោមជ្រែងដល់កូនក្នុងការធ្វើដំណើរឆ្ពោះទៅរកជោគជ័យនៃគោលដៅ។ បរិយាកាសល្អជុំវិញវ័យវឌ្ឍនាការរបស់កូន គឺជាបច្ច័យជួយដល់ការសំរេចនូវគោលដៅមួយចំណែកដ៏ធំផងដែរ ដែលនៅក្នុងភាសាបាលីលោកប្រើពាក្យថា* **បដិរូបទេសវាសៈ** *គឺការរស់នៅក្នុងប្រទេសដែលសមគួរ។*

# ថ្ងៃចូលបរិនិព្វាន




*ព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធ ដែលរក្សាទុកនៅក្នុងសារមន្ទីរជាតិ ក្រុងញូដែល្ហី ប្រទេសឥណ្ឌា*

*រូបថតដោយ ហេង មណីចិន្តា ឆ្នាំ ២០០៧*

*បន្ទាប់ពីត្រាស់ដឹង និងការបំពេញកិច្ចការដើម្បីពិភពលោកអស់រយៈពេលដល់ទៅ៤៥ឆ្នាំ ព្រះពុទ្ធអង្គក៏ទ្រង់ចូលព្រះនិព្វាន(ចូលមរណភាព)ក្នុងព្រះជន្ម៨០វស្សា នាថ្ងៃអង្គារ ១៥កើតខែវិសាខ ឆ្នាំម្សាញ់ នាពេលជិតភ្លឺ។ មរណភាពជាសភាវៈធម្មជាតិដែលមិនមាននរណាអាចគេចបាន មិនថាជាមនុស្សធម្មតាម្នាក់ ឬព្រះពុទ្ធដែលជាអច្ឆរិយបុគ្គលនោះឡើយ។ តែអ្វីដែលគួរផ្ចុះបញ្ចាំងអំពីការចូលព្រះនិព្វាននោះ គឺថា តើមុននឹងម្នាក់ៗចូលមរណភាពនោះ តើម្នាក់ៗបានធ្វើអ្វីខ្លះ ឬគួរធ្វើអ្វីខ្លះជាប្រយោជន៍ដល់ខ្លួន? តើម្នាក់ៗបានបន្សល់ទុកនូវអ្វីខ្លះ ឬគួរបន្សល់ទុកនូវអ្វីខ្លះសំរាប់ជាប្រយោជន៍ដល់សង្គមជាតិ?*

*នៅនាទីចុងក្រោយមុននឹងព្រះពុទ្ធអង្គបរិនិព្វាន ទ្រង់បានត្រាស់ជាចុងក្រោយដល់ភិក្ខុសង្ឃដែលកំពុងគង់ជុំវិញថា៖ «***ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ***»។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ*

តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយមានសេចក្តីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យ សម្រេច ដោយសេចក្តីមិនប្រមាទចុះ។

សារៈសំខាន់របស់ពុទ្ធដីកាត្រង់នេះ តាមទស្សនៈទូទៅ គឺស្ថិតនៅលើប្រយោគថា **ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេច។** ប្រយោគនេះ តែងតែទទួលបានការបកស្រាយនិងយកមកសម្តែងជាធម៌ទេសនាពល់ពេល ដើម្បីជាការដាស់តឿនដល់ខ្លួននិងពុទ្ធបរិស័ទ ដោយពាក្យថា**កិច្ចទាំងពួង**ក្នុងទីនេះ បានដល់កិច្ចដែលមានប្រយោជន៍ដល់ខ្លួន និងកិច្ចដែលមានប្រយោជន៍ដល់អ្នកដទៃ។ ឬម្យ៉ាងទៀត បានដល់កិច្ចដែលមានប្រយោជន៍ដល់ក្នុងជាតិនេះ និងកិច្ចដែលមានប្រយោជន៍ដល់ជាតិមុខ។

ចុះកិច្ចទាំងពួងរបស់ព្រះសម្មាសម្ពុទ្ធដែលព្រះអង្គបានបំពេញឱ្យសម្រេចមុននឹងចូលបរិនិព្វានគឺអ្វីទៅ? មានរឿងនៅក្នុងមហាបរិនិព្វានសូត្រ ក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ ព្រះត្រៃបិដកលេខ១៦ ដែលបានចារទុកថា កាលពីព្រះពុទ្ធអង្គទើបតែបានត្រាស់ដឹងថ្មីៗ ក្រុងមារបានចូលមកអារាធនាឱ្យព្រះអង្គចូលបរិនិព្វាន តែទ្រង់បានឆ្លើយតបទៅនឹងក្រុងមារវិញថា៖««ម្នាលមារមានចិត្តបាប (បើ)ពួកភិក្ខុជាសាវ័ក ពួកភិក្ខុនីជាសាវិកា ពួកឧបាសកជាសាវ័ក ពួកឧបាសិកាជាសាវិការបស់តថាគត ដែលឈ្លាសវៀងវៃ ក្លៀវក្លា ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ នៅមិនទាន់មាន ទាំងមិនទាន់បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន ទាំងមិនទាន់សង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនបានដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យបានដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ។ ម្យ៉ាងទៀត ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចំរើន មិនទាន់ផ្សាយទៅសព្វទិស មិនទាន់ដឹងច្រើនគ្នា ទាំងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតានិងមនុស្សមិនទាន់ចេះសំដែងបានដោយ

ប្រពៃដរាបណាទេ តថាគតក៏មិនទាន់បរិនិព្វានដរាបនោះ"។ ៤៥ឆ្នាំក្រោយមក នៅពេលដែលព្រះអង្គមានព្រះជន្ម៧៩វស្សានិង៩ខែ(៣ខែមុនចូលបរិនិព្វាន) ក្រុងមារក៏បានចូលមកអារាធនាម្តងទៀត ដោយនៅពេលនេះ ព្រះពុទ្ធអង្គទ្រង់សុខចិត្តទទួលអារាធនាព្រមចូលបរិនិព្វាន ដោយព្រះអង្គបានប្រមើល(វាយតម្លៃ) ឃើញថាកិច្ចទាំងពួងរបស់ព្រះអង្គ គឺការបណ្តុះបណ្តាលសមត្ថភាពពុទ្ធបរិស័ទឱ្យបានល្អ និងការបង្កើតាំងអង្គការពុទ្ធសាសនា(ព្រហ្មចារ្យ)របស់ព្រះអង្គឱ្យបានមាំមួននោះ បានទៅដល់គោលដៅហើយ។

ដូច្នេះ ក្នុងឋានៈជាពុទ្ធបរិស័ទនាបច្ចុប្បន្ន កិច្ចទាំងពួងរបស់យើងទៅតាមលំអានរបស់ព្រះពុទ្ធអង្គជាបរមគ្រូ ដែលមានក្នុងមហាបរិនិព្វានសូត្រនោះ គឺៈ

១. គប្បីរៀនដោយប្រពៃ និងបដិបត្តិនូវសតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រីយ៍៥ ពលៈ៥ ពោជ្ឈង្គ៧ និងអរិយមគ្គប្រកបដោយអង្គ៨(ពោធិបក្ខេយ្យធម៌៣៧) ទាល់តែមានភាពឈ្លាសវៀងវៃ ក្លៀវក្លា ជាពហុស្សូត ហើយអាចប្រាប់សំដែង ធ្វើឲ្យងាយបាន នូវធម៌របស់ព្រះអង្គ ទាំងអាចដោះស្រាយនូវពាក្យទិតៀនដែលកើតឡើងហើយ បានដោយល្អតាមពាក្យដែលសមហេតុ និងជាអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រព្រឹត្តតាមធម៌ រហូតទាល់តែបានក្លាយទៅជាបុគ្គលប្រភេទណាមួយ ក្នុងចំណោមបុគ្គលទាំង៤ប្រភេទគឺសោតាបន្នបុគ្គល សកទាគាមិបុគ្គល អនាគាមិបុគ្គល និង អរហត្តបុគ្គល។

២. គប្បីថែទាំសាសនព្រហ្មចរិយៈ(ពុទ្ធសាសនា) ឲ្យបានរឹងមាំល្អខ្ជាប់ខ្ជួន តាំងនៅអស់កាលអង្វែង តាំងនៅអស់កាលដ៏យូរ មានការរីកចំរើន បានផ្សព្វផ្សាយទៅកាន់សព្វទិស ធ្វើឲ្យមហាជនកាន់តែច្រើនបានដឹងពីពុទ្ធសាសនា និងធ្វើឲ្យពុទ្ធសាសនាបានអភិវឌ្ឍន៍ពេញបរិបូណ៌ ដើម្បីជាប្រយោជន៍ដល់ជនដ៏ច្រើន ដើម្បីសេចក្តីសុខដល់ជនដ៏ច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ។

# អនុមោទនាការត្រាស់ដឹង ២៦០០ ឆ្នាំ

*ពួកយើងជាប្រជាពុទ្ធបរិស័ទខ្មែរ មានសំណាងណាស់ ដែលបានរស់នៅទាន់ឆ្នាំនេះ ដើម្បីអនុមោទនាការត្រាស់ដឹងរបស់ព្រះអង្គគ្រប់២៦០០ឆ្នាំ និងជាភ័ព្វល្អពេកណាស់ដែលកូនយើងបានកើតនៅក្នុងឆ្នាំនេះ ដែលជាឆ្នាំដ៏ពិសិទ្ធមិនងាយបានជួបប្រទះ!!!*

*ពួកយើងគួរទៅវត្តដើម្បីធ្វើអនុមោទនាអបអរសាទរ ព្រោះរាជរដ្ឋាភិបាលបានកំណត់យកថ្ងៃអង្គារទី១៧ឧសភា ដែលត្រូវនឹងថ្ងៃធ្វើបុណ្យជាតិវិសាខបូជា ជាថ្ងៃសម្រាប់អបអរសាទរ ដោយការសមាទានសីល៥ ការប្រគេនចង្ហាន់ព្រះសង្ឃនៅពេលព្រឹកនិងថ្ងៃត្រង់ ដោយការដើរហែរប្រទក្សិណជុំវិញព្រះវិហារ ដោយការថ្វាយភ្ញីផ្កា ដោយការសូត្រធម៌រំលឹកសរសើរ ដោយដោយការស្តាប់ធម្មទេសនា និងដោយការសាកសួរសាកច្ឆាធម៌ជាដើមៗ សម្រាប់ពុទ្ធបរិស័ទដែលមិនបានអញ្ជើញទៅវត្តក៏គួរអុជទៀនធូប និងថ្វាយភ្ញីផ្កានៅមុខព្រះពុទ្ធរូបដែលមាននៅនឹងផ្ទះ និងគួរធ្វើអភ័យទានដោយការលើកលែងទោសអ្នកដែលនប្រព្រឹត្តិខុសលើយើង និងលែងសត្វមានជីវិតឲ្យរួចខ្លួន ដូចជាពពួកសត្វត្រី ឬពពួកសត្វបក្សី ជាដើម ដើម្បីជាបុណ្យកុសល សម្រាប់ជីវិតរបស់យើងៗ*

*ដោយហេតុថាឆ្នាំនេះជាឆ្នាំពិសេស ដែលរំលឹកដល់ការដែលព្រះពុទ្ធបរមគ្រូរបស់យើងលោកបានត្រាស់ដឹងជា***ព្រះពុទ្ធ** *ត្រាស់ដឹងជា***ព្រះអរហន្ត** *ត្រាស់ដឹងនូវ* **អរិយសច្ច៤** *ត្រាស់ដឹងនូវ***មជ្ឈិមាបដិបទា** *ត្រាស់ដឹងនូវ***អដ្ឋង្គិកមគ្គ** *ត្រាស់ដឹងនូវ* **និព្វាន** *និងត្រាស់ដឹងនូវព្រះធម៌ដែលជាប្រទីបសម្រាប់បំភ្លឺជីវិតមនុស្សជាតិនោះ ពុទ្ធបរិស័ទទាំងឡាយគួរតែប្រឹងប្រែងបន្ថែមទៀត ក្នុងការរៀន សិក្សា និងបដិបត្តិនូវគោលធម៌ទាំងអស់នេះ ឲ្យកាន់តែច្បាស់និងកាន់តែប្រសើរឡើង និងប្រាប់នូវគោលធម៌ដ៏សំខាន់ៗទាំងនេះ ឲ្យកូន ចៅ និងសាច់ញាតិរបស់ខ្លួនបានដឹងផង ជាពិសេសគឺ*

អរិយសច្ច៤ ដែលជាវិធីជីវិតដែលប្រកបដោយហេតុផល មិនបាច់ពឹងលើព្រេងវាសនា មិនបាច់អង្វរករឲ្យអាទិទេពជួយ តែជាអ្នកកំណត់ជីវិតរបស់ខ្លួនដោយខ្លួនឯង។ យើងអាចមិនមែនជាគ្រូពេទ្យដែលចេះព្យាបាលជម្ងឺអ្នកដទៃ តែយើងអាចប្រើវិធីសាស្ត្ររបស់គ្រូពេទ្យដើម្បីដោះស្រាយបញ្ហាជីវិត ឬសេចក្ដីទុក្ខក្រៀមក្រំក្នុងជីវិតបានដោយការស្គាល់បញ្ហាជីវិតនោះឲ្យបានច្បាស់(ទុក្ខសច្ចៈ) ស្រាវជ្រាវរកឲ្យឃើញថាអ្វីជាដើមហេតុរបស់បញ្ហាដែលកំពុងតែជួបប្រទះនេះ(ទុក្ខសមុទយសច្ចៈ) រៀបចំគោលដៅជីវិតដែលគ្មានបញ្ហាឲ្យបានច្បាស់(ទុក្ខនិរោធៈ) និងដើរតាមផ្លូវទាំង៨(មគ្គសច្ចៈ) ដែលព្រះពុទ្ធអង្គលោកបានពិសោធន៍រួចហើយគឺ ១-មានទស្សនៈត្រូវ ២-មានការគិតត្រូវ ៣-មានការនិយាយស្ដីត្រូវ ៤-មានទង្វើឬកម្មត្រូវ ៥-មានការចិញ្ចឹមជីវិតត្រូវ ៦-មានសេចក្ដីព្យាយាមត្រូវ ៧-មានសតិត្រូវ និង៨-មានសមាធិចិត្តត្រូវ។

ក្រៅពីការយកអរិយសច្ចៈ៤ជាមាគ៌ាជីវិត យើងក៏គួរគិតពិចារណាដែរថា តើក្នុងឋានៈជាពុទ្ធបរិស័ទ យើងនឹងអាចបន្តសាសនព្រហ្មចរិយៈ(**ពុទ្ធសាសនា**) របស់ព្រះបរមគ្រូយើង ឱ្យបានរឹងមាំល្អខ្ជាប់ខ្ជួន មានការរីកចំរើន បានផ្សព្វផ្សាយទៅកាន់សព្វទិស ធ្វើឲ្យមហាជនកាន់តែច្រើនបានដឹងពីពុទ្ធសាសនា និងធ្វើឲ្យពុទ្ធសាសនាបានអភិវឌ្ឍន៍ថែមទៀតដោយរបៀបណា ដើម្បីជាប្រយោជន៍ដល់ជំនាន់កូននិងចៅ និងអនុជនជាន់ក្រោយរបស់យើង។ ព្រោះថា **ពុទ្ធសាសនាដែលនឹងអាចតាំងនៅអស់កាលដ៏យូរបាននោះ ក៏ព្រោះមានទំនាក់ទំនងជាមួយនឹងភាពជាប្រយោជន៍នៃពុទ្ធធម៌ដល់មនុស្សជាតិជនដ៏ច្រើន។** បើមនុស្សជាតិ ជាពិសេសខ្មែរយើង មិនបានយល់ឃើញថាពុទ្ធសាសនាមានប្រយោជន៍ទេនោះ ពុទ្ធសាសនានេះក៏នឹងមិនមានអ្នកណាបដិបត្តិ ជឿ ឬកាន់តាមដែរ។ **ភាពជាប្រយោជន៍របស់ពុទ្ធសាសនា គឺនៅពេលណាដែលខ្មែរយើងយល់ថា អរិយសច្ចៈ៤ នេះ ពិតជាមានប្រយោជន៍ក្នុងការនាំជីវិតឆ្ពោះទៅរកសេចក្ដីសុខពិតប្រាកដមែន ហើយនាំគ្នារស់នៅក្នុងវិថីជីវិតបែបអរិយសច្ចៈនោះ ដោយការពេញចិត្ត និងជឿជាក់។**

*ខ្ញុំគិតថា តួនាទីរបស់ជំនាន់យើងនេះ ជាពិសេសព្រះសង្ឃ មានសារៈសំខាន់ណាស់ដែលត្រូវធ្វើឲ្យភាពមានប្រយោជន៍របស់ពុទ្ធសាសនា កើតមានដល់ប្រជាជនខ្មែរ ដោយចំពោះក្នុងចំណោមយុវវ័យនាសម័យសកលភាវូបនីយកម្មនេះ។* ***យើងគួរតែប្រកាសយកឆ្នាំព.ស.២៥៥៥ ឬឆ្នាំសាកល២០១១នេះ ជាឆ្នាំអរិយសច្ចជាឆ្នាំចាប់ផ្ដើមនៃ ទសវត្សរ៍វិថីជីវិតអរិយសច្ច*** *សម្រាប់ប្រជាជាតិខ្មែរយើង ព្រោះថា បើយើងរស់នៅក្នុងអរិយសច្ច ឈ្មោះថាយើងរស់នៅក្នុងធម៌ទាំង៨៤០០០ របស់ព្រះពុទ្ធ ផងដែរ។*

*សូមឱ្យបុណ្យអានិសង្សនៃការបូជាចំពោះខួបនៃការត្រាស់ដឹងជាពុទ្ធរបស់ព្រះបរមគ្រូនៃយើងគ្រប់២៦០០ឆ្នាំ និងអានិសង្សនៃការបូជាចំពោះថ្ងៃវិសាខបូជានេះ បានជាបច្ច័យជួយឱ្យប្រជាបរិស័ទខ្មែរនិងសកលលោក បានក្លាយទៅជាអ្នកដែលមានការយល់ឃើញត្រឹមត្រូវ គិតត្រឹមត្រូវ និយាយត្រឹមត្រូវ ធ្វើអំពើត្រឹមត្រូវ ប្រកបអាជីវកម្មត្រឹមត្រូវ មានការព្យាយាមត្រឹមត្រូវ តាំងសតិបានត្រឹមត្រូវ និងតម្កល់ចិត្តបានស្ងប់ត្រឹមត្រូវ នៅក្នុងគន្លងនៃផ្លូវដែលមិនតឹងពេកមិនធូរពេក មិនឆ្វេងពេកមិនស្ដាំពេក ដើម្បីសន្តិភាព និងការអភិវឌ្ឍន៍មួយដែលស្ថិតស្ថេរចិរកាល តរៀងទៅហោង។៚*

**សូមអនុមោទនា!**
**សាធុ! សាធុ! សាធុ!**

*ពីទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទ*
*ធម្មបណ្ឌិត ហេង មណីចិន្តា*

# វិសាខបូជា

៙វិសាខភ្លៀងធ្លាក់ត្រជាក់កាយ ពេញបូណ៌ព្រះពាយបក់រំភើយ បក់នាំក្លិនធម៌ក្រអូបស្បើយ
ចេញមកល្ហើយៗពីក្នុងវត្ត។ សម្ដែងពិរោះនៃទេសនា បទស្ទូតនានានាំកំសត់
នឹកឃើញដល់ព្រះចរិយាបទ ដែលព្រះសុគតទ្រង់បំពេញ។ តាំងតែពីពេលទ្រង់ប្រសូត្រ
ព្យាយាមរហូតគ្មានទោម្នេញ លុះត្រាតែបានត្រាស់ពេញលេញ ដរាបចរចេញទៅនិព្វាន។
ដើម្បីប្រែប្រាប់ដំណឹងល្អ ដល់សព្វនិករគ្រប់ទិសស្ថាន ថាមានផ្លូវមួយល្អកុំផាន
ដែលមនុស្សគួរបានដើរលើផ្លូវ។ តម្រង់ទៅរកទីគ្មានទុក្ខ ទីមានតែសុខមានតែត្រូវទី
នោះសប្បាយពន់ពេកក្រូវ តែត្រូវដើរផ្លូវព្រះអង្គប្រាប់។ ព្រោះបើមិនដើរផ្លូវនោះទេ
ទុក្ខទោសនឹងរេមកប្រញាប់ ទុក្ខព្រោះតែកើតព្រោះតែស្លាប់ ទំខ្លួនយើងជាប់ឱ្យឈឺផ្សារ។
ជរាព្យាធិនិងសោកសៅ ទោមនស្សចិត្តក្ដៅព្រោះតណ្ហា កាម-ភព-វិភព បីប្រការ
តណ្ហានេះជាសមុទ័យ។ រលត់សូន្យបានព្រោះមាគ៌ា ផ្លូវព្រះសាស្ដាមានប្រាំបីរក
ឃើញនៅខែពេញបូណ៌មី វិសាខរាត្រីនាំសុខា។ វិសាខមាសាអស្ចារ្យណាស់ ខែ
ព្រះអម្ចាស់ត្រាស់ពុទ្ធា ប្រសូត្រក៏ខែវិសាខា លុះទ្រង់មរណាពិសាខដែរ។
វិសាខមាសាពេញបូណ៌មី គ្រប់ជនប្រុសស្រីជាជាតិខ្មែរ គប្បីចងចាំនិងខំថៃ
ប្រពៃណីកេរ្តិ៍ចេរទៅវត្ត។ ទៅស្ដាប់លោកសូត្រប្រាប់ពីផ្លូវ តម្រង់តម្រូវតាមធម៌បទ
ទៅស្រូបក្លិនធម៌ល្អហ្មត់ចត់ យកមកប្រតិព័ទ្ធក្នុងចិន្ដា។ ក្រែងអើនឹងបានរួចពីទុក្ខ
ជួបសុខក្សេមក្សាន្ដក្នុងអាត្មា ព្រោះបានស្ដាប់ធម៌ព្រះសាស្ដា វិសាខបូជាខែពេញវង់។៚

«ម្នាលភិក្ខុទាំងឡាយ (បើ)អ្នកទាំងឡាយគួរអនុគ្រោះចំពោះជនពួកណាមួយ ឬជនជាមិត្តក្ដី ជាអាមាត្យក្ដី ជាញាតិក្ដី ជាសាលោហិតក្ដី គប្បីអនុគ្រោះជននោះនូវពាក្យដែលគួរស្ដាប់ចុះ ម្នាលភិក្ខុទាំងឡាយ គឺអ្នកទាំងឡាយគួរញ៉ាំងជនទាំងនោះឲ្យសមាទាន ឲ្យតាំងនៅ ឲ្យដំកល់នៅក្នុងការត្រាស់ដឹងនូវអរិយសច្ចៈ៤ តាមសេចក្ដីពិត។ អរិយសច្ចៈ៤គឺអ្វីខ្លះ។ គឺការដឹងទុក្ខ ការដឹងហេតុជាទីកើតឡើងនៃទុក្ខ ការដឹងទីរំលត់ទុក្ខ និងការដឹងបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ។»